01672677

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D269/4

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៦)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 06 / 2021
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គបុរេជំនុំជម្រះ**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន |
| | ចៅក្រម Olivier BEAUVALLET |
| | ចៅក្រម និយ ថុល |
| | ចៅក្រម Kang Jin BAIK |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ៖ | ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី យឹម ទិត្យ:**

អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រ៊ីនណា
វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

# មាតិកា

**I. ប្រវត្តិនីតិវិធី** ........ ១

**II. មូលដ្ឋាននៃការត្រួតពិនិត្យឡើងវិញ** ........ ១៥

**III. ភាពអាចទទួលយកបាន** ........ ១៦

**IV. គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី** ........ ១៧

**V. អង្គសេចក្តី** ........ ២១

**VI. ផ្នែកសម្រេចសេចក្តី** ........ ២២

**VII. មតិរបស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម នំយ ថុល និងចៅក្រម ហួត វុទ្ធី** ........ ២៣

**VIII. មតិរបស់ចៅក្រម OLIVIER BEAUVALLET និងចៅក្រម KANG JIN BAIK** ........ ២៤

ក. មូលដ្ឋានទី ១៖ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងអង្គហេតុ ដោយគ្រាន់តែកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងដែនសមុទ្រ និងដែនកោះជិតឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យថាជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវពីទំនាក់ទំនង អនុលោមតាមវិធាន ២៣*ស្ទួន* (ខ)(១) វិធានផ្ទៃក្នុង ........ ២៤

១. សារណា ........ ២៤

២. ការពិភាក្សា ........ ៣០

ក. ច្បាប់ជាធរមាន ........ ៣០

ខ. មូលដ្ឋានទី ១(១). ........ ៣១

គ. មូលដ្ឋានទី ១(២). ........ ៣៧

ឃ. មូលដ្ឋានទី ១(៣) ........ ៤២

ខ. មូលដ្ឋានទី ២៖ ការចោទប្រកាន់អំពីកំហុសដែលពាក់ព័ន្ធនឹងផលប៉ះពាល់កើតចេញពីដីកាសម្រេច ស្របតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង ........ ៤៦

១. សារណា ........ ៤៦

២. ការពិភាក្សា ........ ៤៧

គ. មូលដ្ឋានទី៣៖ ការចោទប្រកាន់អំពីកំហុសនៃការខកខានមិនបានផ្តល់នូវសេចក្តីសម្រេចមួយ ដោយមានសំអាងហេតុ សម្រាប់ការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ ៥១

១. សារណា ........ ៥១

២. ការពិភាក្សា ..... ៥៣

ឃ. មូលដ្ឋានទី៤៖ ការចោទប្រកាន់អំពីកំហុសដោយការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារការខកខានពុំបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ ..... ៥៨

១. សារណា ..... ៥៨

២. ការពិភាក្សា ..... ៦១

ឃ. សេចក្តីសន្និដ្ឋាន ..... ៦៥

01672680



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវី") កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ("បណ្ដឹងឧទ្ធរណ៍" ឬ "បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានចុះហត្ថលេខាលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ដោយស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការទាក់ទងនឹងការចោទប្រកាន់ដែលអាចសំដៅដល់ការទទួលខុសត្រូវរបស់ ស៊ូ ម៉េត និង មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[2]។

2. នៅថ្ងៃដដែលនេះដែរ អនុលោមតាមវិធានផ្ទៃក្នុង ៧១(២)[3] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិពុំយល់ស្របនឹងការចោទប្រកាន់លើបទល្មើសថ្មីៗ ដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ[4]។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួនចំពោះការខ្វែងយោបល់គ្នានេះ ដោយបានសន្និដ្ឋានថា អង្គជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនតាមការតម្រូវ ដើម្បីធ្វើសេចក្ដីទៅលើបញ្ហាខ្វែងយោបល់គ្នានេះទេ ហើយអនុលោមតាមវិធាន ៧៤(១) និង ៥៣(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") បណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ ("បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3)")។

[2] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ (D1)")។

[3] *វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (វិ.លើកទី៩) ត្រូវបានធ្វើវិសោធនកម្មថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") វិធាន ៧១(២)។

[4] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្ដីប្រកាសជាលាយលក្ខណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីអង្គហេតុ និងសំអាងហេតុសម្រាប់ករណីខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ ១។

ដើម្បីបើកកិច្ចស៊ើបសួរ[5]។

3. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចាប់ផ្តើមកិច្ចស៊ើបសួរប្រឆាំងនឹង មាស មុត ជាផ្នែកនៃសំណុំរឿង ០០៣ ដែលក្នុងចំណោមនោះ ពាក់ព័ន្ធនឹងការចោទប្រកាន់មួយចំនួនពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦") និងបានដាក់សំណុំរឿងនេះជូនសហចៅក្រមស៊ើបអង្កេត[6]។ ការចោទប្រកាន់បន្ថែមត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលបានដាក់កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")[7]។

4. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា ពួកគាត់បានសម្រេចថា កិច្ចស៊ើបសួរតាមផ្លូវតុលាការលើសំណុំរឿង ០០៣ បានបញ្ចប់ហើយ ("សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ឆ្នាំ២០១១")[8]។ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ លោកចៅក្រម Blunk បានលាលែងពីតំណែង[9] ហើយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានចេញដីកាសម្រេចស្តីអំពីការបើកកិច្ចស៊ើបអង្កេតបឋមឡើងវិញ[10]។

---

[5] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ៤៥។

[6] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[7] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (ឯកសារ D120"))។

[8] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីការបិទការស៊ើបសួរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D13 ("សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ឆ្នាំ២០១១ (D13)")។

[9] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-24%2016%3A37/E189_3_1_1.1.3_EN.pdf (ចូលមើលចុងក្រោយនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១)។

[10] សំណុំរឿង ០០៣ ដីកាសម្រេចអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D28។

5. ចាប់តាំងពីពេលចាប់ផ្ដើមការស៊ើបអង្កេតមក មានប្រជាជនចំនួន ៦៤៦ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[11]។

6. ក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលដំណឹងថា អ្នកដាក់ពាក្យសុំចំនួន ១៨ នាក់ បានទទួលមរណភាព[12] ហើយពុំមានការដាក់ពាក្យសុំបន្តបណ្ដឹងរដ្ឋប្បវេណីក្នុងនាមអ្នកដែលបានទទួលមរណភាពទេ។ ក្រៅពីនេះ មានអ្នកដាក់ពាក្យសុំម្នាក់បានដកពាក្យសុំរបស់ខ្លួនវិញ[13]។

7. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ និងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានប្រកាសថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ សេង ច័ន្ទធារី, Robert HAMILL, ជុំ នៅ និង Timothy Scott DEEDS មិនអាចទទួលស្គាល់បានទេ[14]។ អ្នក

---

[11] សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 ("ដីកាសម្រេចលើភាពអាចទទួលស្គាល់ (D269)") កថាខណ្ឌ ២។

[12] សំណុំរឿង ០០៣ អនុស្សរណៈអន្តរការិយាល័យពីអង្គភាពគាំពារការការពារក្ដី ផ្ញើជូនការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព ឧបសម្ព័ន្ធ ឃ នៃដីកាសម្រេចលើភាពអាចទទួលស្គាល់ (D269) ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ឯកសារ D269.4។ សំណុំរឿង ០០៣ បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ដែលទទួលមរណភាព និងចូលរួមក្នុងសំណុំរឿង ០០៣ & ០០៤ របស់អង្គភាពគាំពារជនរងគ្រោះ ឧបសម្ព័ន្ធ ង នៃដីកាសម្រេចលើភាពអាចទទួលស្គាល់ (D269) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269.5។ សំណុំរឿង ០០៣ តារាងដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលមរណភាព ឧបសម្ព័ន្ធ ២ នៃដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ D246.2។ សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/០១") ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D307 កថាខណ្ឌ ៧។

[13] សំណុំរឿង ០០៣ លិខិតពីក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតផ្ញើជូនមេធាវី សំ សុគង់ និង មេធាវី Nushin SARKARATI ពាក់ព័ន្ធនឹងការដកខ្លួនរបស់លោក ឌី ដានី ចេញពីសំណុំរឿង ០០៣, ០០៤ និង ០០៤/២ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ឯកសារ D11/587/3។

[14] សំណុំរឿង ០០៣ ដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ច័ន្ទធារី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D11/1/3 ("ដីកាសម្រេចស្ដីពីការទទួលយក សេង ច័ន្ទធារី (D11/1/3)")។ សំណុំរឿង ០០៣ ដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Rob HAMILL ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D11/2/3 ("ដីកាសម្រេចស្ដីពីការទទួលយក Rob HAMILL (D11/2/3)")។ សំណុំរឿង ០០៣ ដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជុំ នៅ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D11/3/3 ("ដីកាសម្រេចស្ដីពីការ

ដាក់ពាក្យសុំបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[15]។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ថ្ងៃទី១៣ និងទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួន ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ពីម្ចាស់បណ្ដឹងឧទ្ធរណ៍ទាំង ៤ នាក់ ដោយប្រកាសថា អង្គជំនុំជម្រះមិនអាចទទួលបានសំឡេងភាគច្រើនចាំបាច់ ដើម្បីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍បានទេ[16]។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ សេង ច័ន្ទធារី បានដកពាក្យសុំរបស់ខ្លួន[17] ដែលត្រូវបានទទួលស្គាល់ដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត តាមរយៈលិខិតមួយច្បាប់នៅថ្ងៃទី២៩ ខែ

---

ទទួលយក ជុំ នៅ (D11/3/3)")។ សំណុំរឿង ០០៣ ដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Timothy Scott DEEDS ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ D11/4/3 ("ដីកាសម្រេចស្ដីពីការទទួលយក Timothy Scott DEEDS (D11/4/3)")។

15 សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ច័ន្ទធារី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ឯកសារ D11/1/4/1។ សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១ ឯកសារ D11/2/4/2។ សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ជុំ នៅ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ឯកសារ D11/3/4/1។ សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Timothy Scott DEEDS (D11/4/3) ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ ឯកសារ D11/4/4/1។

16 សំណុំរឿង ០០៣ (អបជ០២) សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី Robert HAMILL ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ឯកសារ D11/2/4/4 កថាខណ្ឌ ១២-១៣។ សំណុំរឿង ០០៣ (អបជ០១) សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សេង ច័ន្ទធារី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D11/1/4/2 កថាខណ្ឌ ៨-៩។ សំណុំរឿង ០០៣ (អបជ០៥) សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជុំ នៅ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារD11/3/4/2 កថាខណ្ឌ ១០-១១។ សំណុំរឿង ០០៣ (អបជ០៧) សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី Timothy Scott DEEDS ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D11/4/4/2 កថាខណ្ឌ ៩-១០។

17 សំណុំរឿង ០០៣ លិខិតពីមេធាវី សំ សុគង់ និង មេធាវី Emmanuel JACOMY ផ្ញើជូនក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងការដកខ្លួនរបស់អ្នកដាក់ពាក្យសុំ សេង ច័ន្ទធារី ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ឯកសារ D11/1/5។

ឧសភា ឆ្នាំ២០១៤[18]។ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ និងថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានពិចារណាសាជាថ្មីទៅលើពាក្យសុំរបស់ Robert HAMILL, Timothy Scott DEEDS និង ជុំ នៅ ហើយបានប្រគល់ឋានៈឱ្យពួកគេជាដើមបណ្តឹងរដ្ឋប្បវេណី[19]។

8. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិក៏បានទទួលយកអ្នកដាក់ពាក្យសុំ ៦ នាក់ទៀតជាដើមបណ្តឹងរដ្ឋប្បវេណី[20]។

9. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានជូនដំណឹងដល់ ស៊ូ

---

[18] សំណុំរឿង ០០៣ លិខិតពីក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី ជួង ជូងី ពាក់ព័ន្ធនឹងការដកខ្លួនរបស់កញ្ញា សេង ច័ន្ទធារី ចេញពីសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D11/1/6។ សំណុំរឿង ០០៣ លិខិតពីក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី សំ សុគង់ ពាក់ព័ន្ធនឹងការដកខ្លួនរបស់កញ្ញា សេង ច័ន្ទធារី ចេញពីសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D11/1/7។ សំណុំរឿង ០០៣ លិខិតពីក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី Emmanuel JACOMY ពាក់ព័ន្ធនឹងការដកខ្លួនរបស់កញ្ញា សេង ច័ន្ទធារី ចេញពីសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D11/1/8។

[19] សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការពិចារណាឡើងវិញ លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert HAMILL ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D11/2/5/1 កថាខណ្ឌ ៣៦-៣៧។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការពិចារណាឡើងវិញលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Timothy Scott DEEDS ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ឯកសារ D11/4/5 កថាខណ្ឌ ៣៤-៣៥។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការពិចារណាឡើងវិញលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជុំ នៅ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/3/5 កថាខណ្ឌ ៣១-៣២។

[20] សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង សុភាព ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/8/3 កថាខណ្ឌ ២៣។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆែ ហៀប ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/39/3 កថាខណ្ឌ ២៧។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខៀវ ខាន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/214/3 កថាខណ្ឌ ២៤។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ថោង ចាន់ណា ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/243/3 កថាខណ្ឌ ១៥។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អួម ម៉ុន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/305/3 ។ សំណុំរឿង ០០៣ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី មួន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ឯកសារ D11/308/3 កថាខណ្ឌ ១៥។

ម៉េត និង មាស មុត ថា ពួកគេគឺជាជនសង្ស័យក្នុងសំណុំរឿង ០០៣ និងបានជូនដំណឹងស្ដីពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានតំណាងផ្លូវច្បាប់ តាមជម្រើសរបស់ពួកគេ ហើយពួកគេមានសិទ្ធិចូលមើលសំណុំរឿងបាន[21]។

10. សំណុំរឿងរបស់ មាស មុត ស្ថិតក្រោមការខ្វែងយោបល់គ្នាជាសម្ងាត់មួយចំនួនរវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ (ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និង ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨)[22]។ ពុំមានករណីខ្វែងយោបល់ណាមួយត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះទេ។

11. នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីទាំងអស់ថា ស៊ូ ម៉េត បានស្លាប់ហើយ[23] ហើយបន្ទាប់មក កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានបញ្ចប់នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥[24]។

12. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ មាស មុត *ដោយ*កំបាំង*មុខ* ("ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ*)[25] និងបានបញ្ជាក់កម្ពិតពីបទចោទនៅក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងដីកាសម្រេចស្ដីពី ("ការជូនដំណឹងអំពីបទចោទ

---

[21] សំណុំរឿង ០០៣ ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ] ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D30 (ទាក់ទងនឹង មាស មុត) កថាខណ្ឌ ១, ៤។ សំណុំរឿង ០០៣ ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D31 (ទាក់ទងនឹង ស៊ូ ម៉េត) កថាខណ្ឌ ១, ៤។

[22] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)") កថាខណ្ឌ ៥, ៧, ១៥, ២៧។

[23] សំណុំរឿង ០០៣ ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់ នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ឯកសារ D86។

[24] សំណុំរឿង ០០៣ ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D86/3 ("ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ (ឯកសារ D86/3)")។

[25] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។

ប្រកាន់")[26] ដែលសហមេធាវីការពារក្តី មាស មុត បានប្តឹងឧទ្ធរណ៍ជំទាស់តវ៉ា នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥[27] និងនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ដោយឡែកៗពីគ្នា[28]។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ និងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេច និងសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ទាំងនេះ[29]។

13. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ក្នុងពេលបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកែប្រែបទចោទប្រកាន់មួយចំនួនប្រឆាំងនឹងគាត់[30] បានជូនដំណឹងគាត់អំពីការកំណត់បទចោទបន្ថែមទៀត ចំពោះអំពើប្រល័យពូជសាសន៍ និងការរំលោភសេពសន្ថវៈ ហើយបានចោទប្រកាន់គាត់បន្ថែមចំពោះបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទី

---

[26] សំណុំរឿង ០០៣ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ និងដាក់នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D128.1។

[27] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128/1/3។

[28] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត HARMON អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128.1/1/3។

[29] សំណុំរឿង ០០៣ (អបជ២២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត HARMON អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D128.1/1/11។ សំណុំរឿង ០០៣ (អបជ២១) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D128/1/9 ("សេចក្តីពិចារណាលើការដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (D128/1/9)")។

[30] សូមមើល សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ D174 ("កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (D174)") ទំព័រ ១៥-១៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រកាសថា បទចោទប្រកាន់ខាងក្រោមត្រូវបានលុបចោលរួមមាន៖ ១) ការធ្វើទារុណកម្មនៅវត្តឥន្ទញាណ យោងតាមមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ២) មនុស្សឃាតដោយចេតនា ទាក់ទងនឹងកម្មាភិបាលស៊ីវិលនៅតំបន់ ៥០៥ ខេត្តក្រចេះ ៣) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងកម្មាភិបាលស៊ីវិលនៅតំបន់ ៥០៥ ខេត្តក្រចេះ ៤) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការបោសសម្អាតជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជាជនក្បត់ នៅកំពង់សោម ៥) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងកម្មាភិបាលកងពលលេខ ១១៧ និងកម្មាភិបាលតំបន់ ៥០៥ ខេត្តក្រចេះ ៦) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងជនបរទេស ក្រៅពីជនជាតិវៀតណាម និងថៃ និង ៧) ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុ "ជាតិពន្ធុ"។

ក្រុងហ្សឺណែវ និងការរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[31]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រកាសថា (១) ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ លែងមានសុពលភាព ហើយដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ត្រូវលុបចោល និង (២) បទចោទប្រកាន់នានានៅក្នុងដីកាសម្រេច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ដែលបានដាក់គាត់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ*លែងមានសុពលភាព ហើយបទចោទដែលបានធ្វើឡើងនៅក្នុងការបង្ហាញខ្លួនលើកដំបូងនេះគឺជាបទចោទប្រកាន់ស្ថាពរប្រឆាំងនឹង មាស មុត[32]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ដោយប្រកាសនូវបទចោទទាំងនេះនៅថ្ងៃដដែលនោះ[33]។

14. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ភាគីថា គាត់មានបំណងដកអង្គហេតុមួយចំនួនចេញពីការស៊ើបអង្កេត និងបានស្នើសុំឱ្យភាគីបញ្ចេញមតិយោបល់ទៅលើបញ្ហានោះ (“សំណើសុំមតិយោបល់”)[34]។ ក្រោយពេលទទួលបានមតិយោបល់ពីសហមេធាវីការពារក្តី មាស មុត[35] និងសហព្រះរាជអាជ្ញាអន្តរជាតិ[36] នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ ទាក់ទងនឹងការចោទប្រកាន់នីមួយៗ (“សេចក្តីជូនដំណឹងអំពីការផ្អាកបណ្តោះអាសន្ន”)[37]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហ

---

[31] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (D174) ទំព័រ ២-៩។

[32] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង (D174) ទំព័រ ១៥-១៦។

[33] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក “សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣” ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ https://eccc.gov.kh/sites/default/files/media/ECCC%20PR%2014%20Dec%202015%20En.pdf (ចូលមើលចុងក្រោយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១)។

[34] សំណុំរឿង ០០៣ សំណើសុំមតិយោបល់ទាក់ទិននឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ឯកសារ D184 (“សំណើសុំមតិយោបល់ (D184)”)។

[35] សំណុំរឿង ០០៣ ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី មាស មុត ទៅនឹងសំណើសុំមតិយោបល់ទាក់ទិននឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ (D184) ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ឯកសារ D184/1 (“ចម្លើយតបរបស់ មាស មុត ទៅលើសំណើសុំមតិយោបល់ (D184/1)”)។

[36] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំមតិយោបល់ទាក់ទិននឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D184/2 (“ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំមតិយោបល់ (D184/2)”)។

[37] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ D184/3 (“សេចក្តីជូនដំណឹងអំពីការផ្អាកបណ្តោះអាសន្ន (D184/3)”)។

មេធាវី") មិនបានឆ្លើយតបទៅនឹងសំណើសុំមតិយោបល់ ឬ សេចក្តីជូនដំណឹងអំពីការផ្អាកបណ្តោះអាសន្នទេ។

15. នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងរបស់ខ្លួន អនុលោមតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង ("សេចក្តីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង")[38] ដែលគាត់បានជូនដំណឹងជាផ្លូវការដល់ភាគីពីចេតនារបស់គាត់ ក្នុងការដកអង្គហេតុមួយចំនួនដែលបានចោទប្រកាន់ថែមទៀត និងបានអញ្ជើញឲ្យភាគីដាក់សារណាក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង[39]។ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង[40]។ សហមេធាវី និងសហមេធាវីការពារក្តី មាស មុត មិនបានឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងទេ។

16. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីសម្រេចរបស់គាត់ កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកអង្គហេតុនានាដែលបានចោទប្រកាន់ចេញយោងតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ("ដីកាសម្រេចយោងតាមវិធាន *៦៦ស្ទួន* នៃវិធានផ្ទៃក្នុង")[41]។ ពុំមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទេ។

17. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងលើកទីមួយអំពីការបិទការស៊ើបសួរ ("សេចក្តីជូនដំណឹងលើកទីមួយស្របតាមវិធាន៦៦(១)")[42]។

---

[38] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D184/4 ("សេចក្តីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង (D184/4)")។

[39] សេចក្តីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង (D184/4) កថាខណ្ឌ ៨-៩។

[40] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង "សេចក្តីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង" របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D184/4/1 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សេចក្តីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង (D184/4/1)")។

[41] សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226 ("ដីកាសម្រេចយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* (D226)")។

[42] សំណុំរឿង ០០៣សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D225 ("សេចក្តីជូនដំណឹងលើកទីមួយស្របតាមវិធាន៦៦(១) (ឯកសារ D225)"។

18. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ និងថ្ងៃទី៣១ មករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្គាប់ឱ្យមានតំណាងផ្លូវច្បាប់សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់[43]។

19. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធរាល់ពាក្យសុំ វិធានការការពារទាំងអស់ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ នៅក្នុងសំណុំរឿង ០០៣[44]។

20. នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹង លើកទី២ ស្តីពីការបិទកិច្ចស៊ើបសួរ[45]។

21. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើសុំឱ្យបដិសេធបទចោទប្រកាន់ទាំងអស់ចោល[46] ហើយនៅថ្ងៃដដែលនេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើសុំឱ្យចោទប្រកាន់ មាស មុត និងបញ្ជូនគាត់ទៅជំនុំជម្រះ[47]។

22. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ ដោយបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំង មាស មុត ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[48] ចំណែកសហចៅក្រម

---

[43] សំណុំរឿង ០០៣ ដីកាចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D218។ សំណុំរឿង ០០៣ ដីកាចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ផ្សេងទៀត ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ឯកសារ D230។

[44] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ D246។

[45] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងលើកទី ២ ស្តីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D252 ("សេចក្តីជូនដំណឹងលើកទី ២ ស្តីពីការបិទកិច្ចស៊ើបសួរ (D252)")។

[46] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/6។

[47] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/7។

[48] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)។

ស៊ើបអង្កេតជាតិវិញបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត[49] ("ដីកាសម្រេចលើកលែងចោទប្រកាន់") (ហៅជារួមថា "ដីកាដំណោះស្រាយ")។ ដីកាដំណោះស្រាយត្រូវបានដាក់ជូនដាច់ដោយឡែកពីគ្នា ជាភាសាអង់គ្លេស និងភាសាខ្មែរតែប៉ុណ្ណោះ រីឯសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ។

23. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិបានចេញ "ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" របស់ខ្លួន ("ដីកាសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី") ដោយបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៤២ នៅក្នុងសំណុំរឿង ០០៣ ដែលបានដាក់ក្រោយថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ ដែលគាត់បានចាត់ទុកថាជាកាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[50]។ ដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេតជាតិមិនបានពិនិត្យជាក់លាក់ទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ[51]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាស្តីពីភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("ដីកាស្តីពីភាពអាចទទួលយកបាន") ដោយឡែកមួយ ដោយប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក នៃដីកានោះ ដោយបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ខ នៃដីកានោះ[52]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ថា គាត់នឹងវាយតម្លៃឡើងវិញ ហើយក្នុងករណីចាំបាច់ នឹងធ្វើការពិចារណាឡើងវិញទៅលើសេចក្តីសន្និដ្ឋានស្តីពីភាពអាចទទួលយកបាន ដែលបានធ្វើឡើងនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ និងថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ដោយសហចៅក្រមស៊ើប

---

[49] ដីកាសម្រេចលើកលែងចោទប្រកាន់ (D266)។

[50] សំណុំរឿង ០០៣ ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D268 ("ដីកាសម្រេចលើភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D268)") កថាខណ្ឌ ៩-១១។

[51] ដីកាសម្រេចលើភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D268) កថាខណ្ឌ ១០។

[52] ដីកាស្តីពីភាពអាចទទួលយកបាន (D269) កថាខណ្ឌ ៤៩-៥០។ សំណុំរឿង ០០៣ បញ្ជីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលយក ឧបសម្ព័ន្ធ ក នៃ ដីកាស្តីពីភាពអាចទទួលយកបាន (D269) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269.1 ("ឧបសម្ព័ន្ធ ក នៃ ដីកាស្តីពីភាពអាចទទួលយកបាន (D269.1)")។ សំណុំរឿង ០០៣ បញ្ជីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទទួលយក ឧបសម្ព័ន្ធ ខ នៃ ដីកាស្តីពីភាពអាចទទួលយកបាន (D269) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269.2 ("ឧបសម្ព័ន្ធ ខ នៃ ដីកាស្តីពីភាពអាចទទួលយកបាន (D269.2)")។

អង្កេតបឋមរុងអន្តរជាតិ "ដោយយោងលើការវិវត្តនៃកិច្ចស៊ើបសួរ"[53]។

24. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ សហមេធាវីបានដាក់សំណើបន្ទាន់មួយសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី និងសុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍របស់តែមួយភាសាសិន ចំណែកសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ[54]។

25. នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ សំណៅបកប្រែជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងឧបសម្ព័ន្ធ ខ នៃដីកាស្តីពីភាពអាចទទួលយកបាន ត្រូវបានជូនដំណឹង[55]។

26. នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានទទួលយកសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ដោយពន្យារកាលបរិច្ឆេទចុងក្រោយនៃការដាក់ឯកសាររហូតដល់ ៣០ ពីថ្ងៃជូនដំណឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាខ្មែរ និង ឧបសម្ព័ន្ធ ខ នៃដីកាស្តីពីភាពអាចទទួលយកបាន បន្ថែមចំនួនទំព័រកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ដល់ទៅ ៤៥ ទំព័រជាភាសាអង់គ្លេស ឬភាសាបារាំង ឬ ៩០ ទំព័រ ជាភាសាខ្មែរ និងអនុញ្ញាតឲ្យសហមេធាវីដាក់តែមួយភាសាសិន ជាភាសាអង់គ្លេស ឬភាសាខ្មែរ ចំណែកសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ[56]។

27. នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ សំណៅបកប្រែជាភាសាអង់គ្លេសត្រឹមត្រូវនៃដីកាសម្រេចលើក

---

[53] ដីកាស្តីពីភាពអាចទទួលយកបាន (D269) កថាខណ្ឌ ៥។

[54] សំណុំរឿង ០០៣ សំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ និងដាក់នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ឯកសារ D269/1។

[55] សំណុំរឿង ០០៣ អ៊ីមែលអំពីសេចក្តីជូនដំណឹងពីមន្ត្រីគ្រប់គ្រងសំណុំរឿង ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងការបកប្រែជាភាសាខ្មែរនៃឯកសារ D267 និង D269.2។

[56] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D269/2 ("សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេល និងបន្ថែមចំនួនទំព័រកំណត់ (D269/2)") ទំព័រ ៥។

01672692



លែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវបានជូនដំណឹង[57]។

28. នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ សហមេធាវីបានដាក់ជូនអង្គបុរេជំនុំជម្រះនូវ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្តីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ("បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី")[58]។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ដីកាស្តីពីភាពអាចទទួលយកបានមានកំហុសលើអង្គច្បាប់ និងអង្គហេតុ និងស្នើសុំក្នុងចំណោមនោះថា ដីកាស្តីពីភាពអាចទទួលយកបានគួរត្រូវបានច្រានចោល ហើយអង្គបុរេជំនុំជម្រះគួរពិចារណាឡើងវិញនូវភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ[59]។ ពុំមានភាគីណាមួយដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីទេ។

29. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ សហមេធាវីការពារក្តី មាស មុត បានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត[60]។ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ[61]។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្តីជូនដំណឹង អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[62]។ ភាគីបានដាក់សារណាលើបណ្តឹងឧទ្ធរណ៍ និងចម្លើយតបនានា[63]

---

[57] សំណុំរឿង ០០៣ អ៊ីមែលនៃសេចក្តីជូនដំណឹងពីមន្ត្រីគ្រប់គ្រងសំណុំរឿង ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងការបកប្រែឯកសារ D266 ជាភាសាអង់គ្លេស។

[58] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3)។

[59] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៦០-៦១។

[60] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D267/1។

[61] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D266/1។

[62] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D267/2។

[63] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3។ សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំង

ហើយអំណះអំណាងផ្ទាល់មាត់ទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានស្ដាប់ជាអសាធារណៈ នៅថ្ងៃទី២៧ ទី២៧ និងទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩[64]។

30. នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណាររបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយធ្វើការសន្និដ្ឋានក្នុងចំណោមនោះថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ ដោយរំលោភទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ហើយថា ផ្អែកលើសំអាងហេតុរួម អង្គជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលប់តាមការតម្រូវ ដើម្បីចេញសម្រេចទៅលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះ

---

នឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2។ សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4។ សំណុំរឿង ០០៣ ចម្លើយរបស់ មាស មុត តបទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D266/5។ សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/9។ សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/10។ សំណុំរឿង ០០៣ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយរបស់ មាស មុត ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ និងដាក់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ D267/11។ សំណុំរឿង ០០៣ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ D266/7 និង ឯកសារ D267/12។

[64] សវនាការជាសាធារណៈរួមមាន សេចក្ដីផ្ដើម និង ការអានរបាយការណ៍សំណុំរឿង នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ព្រមទាំងការតាំងសំណួរពីចៅក្រមដល់ភាគី នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ *សូមមើល* សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ (CS) ឯកសារ D266/16.1 និង ឯកសារ D267/21.1។ សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ (CS) ឯកសារ D266/17.1 និង ឯកសារ D267/22.1។ សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ (CS) ឯកសារ D266/18.1 និង ឯកសារ D267/23.1។ សំណុំរឿង ០០៣ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D266/18.2 និង ឯកសារ D267/23.2។

ស្រាយបានទេ[65]។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាដំណោះស្រាយទាំងពីរមានសុពលភាពដូចគ្នា ហើយថា សំណុំរឿងប្រឆាំង មាស មុត គប្បីបញ្ជូនទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក[66]។ ចៅក្រមអន្តរជាតិសម្រេចថា ដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺទុកជាមោឃៈ ហើយការចេញដីកានេះគឺហួសដែនសមត្ថកិច្ច និងសម្រេចទៀតថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសុពលភាព ហើយថា មាស មុត គប្បីបញ្ជូនទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុវត្តគោលការណ៍នៃការបន្តការចោទប្រកាន់[67]។

## II. បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ

31. វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុងតម្រូវថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលព្យាយាមច្រានចោលដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញថា ដីកាសម្រេចដែលរងការជំទាស់ ត្រូវបានធ្វើឡើងផ្អែកលើកំហុសអង្គច្បាប់ និង/ឬកំហុសអង្គហេតុ[68]។ អង្គបុរេជំនុំជម្រះសូមរម្លឹកថា ចំពោះបណ្ដឹងឧទ្ធរណ៍ កំហុសអង្គច្បាប់

[65] សំណុំរឿង ០០៣ (អបជ៣៥) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 ("សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 & D267/35)") ទំព័រ ៥៦។

[66] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 & D267/35) ទំព័រ ៥៧-៥៨។

[67] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 & D267/35) កថាខណ្ឌ ២៦១-២៦២, ២៨៤, ៣៤២-៣៤៣។

[68] វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") (អបជ៥៨) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 ("សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6 )") កថាខណ្ឌ ២៨។ សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") សាលដីកាលើគ្រប់ណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 ("សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4)") កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេតលើភាពអាច

ដែលត្រូវបានចោទប្រកាន់ ត្រូវត្រួតពិនិត្យជាថ្មីឡើងវិញ (*de novo*) ដើម្បីសម្រេចថាតើសេចក្តីសម្រេចអង្គច្បាប់ ត្រឹមត្រូវដែរឬទេ ចំណែកកំហុសអង្គហេតុដែលត្រូវបានចោទប្រកាន់ ត្រូវត្រួតពិនិត្យតាមបទដ្ឋាននៃភាពសមហេតុផល ដើម្បីសម្រេចថាតើមានអ្នកវិនិច្ឆ័យលើអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេច ចំពោះអង្គហេតុដែលចោទជាបញ្ហានេះដែរឬទេ[69]។

## III. ភាពអាចទទួលយកបាន

32. សហមេធាវីបានប្តឹងឧទ្ធរណ៍ ទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុង ហើយបានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍បានដាក់ទាន់ពេលវេលា និងអនុលោមទៅតាមការកំណត់ចំនួនទំព័រ[70]។

33. អង្គបុរេជំនុំជម្រះសូមរំឭកថា អនុលោមតាមវិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង "ដើមបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត [...] ដែលប្រកាសពីការមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[71]។ វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុង បានចែងថា បណ្តឹងឧទ្ធរណ៍ត្រូវដាក់ "ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេច អំពីភាពអាចទទួលយក

---

ទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6)") កថាខណ្ឌ ៣៥។

[69] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6 ) កថាខណ្ឌ ២៨។ សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៣៨១ យោងទៅ សំណុំរឿង ០០២ (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។ សំណុំរឿង ០០២ សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ ៨៩-៩០។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៥។

[70] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៦-៧។

[71] វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៣។

01672696



បាន នូវពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី"[72]។ អង្គជំនុំជម្រះពិចារណាថា បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ដោយអនុលោមទៅតាមការណែនាំរបស់ខ្លួន ដោយរំឮកអំពីសេចក្តីសម្រេច របស់អង្គជំនុំជម្រះ ក្នុងការអនុញ្ញាតជាករណីពិសេស នូវការពន្យាពេលរយៈពេល៣០ថ្ងៃ សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍[73]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## IV. គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី

34. ក្នុងការវាយតម្លៃលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវី អង្គបុរេជំនុំជម្រះពិចារណាថា ជាការសមស្របក្នុងការរំឮកឡើងវិញ នូវគោលការណ៍គតិយុត្តិនានាដែលគ្រប់គ្រងលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខ អ.វ.ត.ក។

35. វិធាន ២៣ ស្ទួន (១) នៃវិធានផ្ទៃក្នុង បានកំណត់នូវលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី៖

> ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវៈ
> ក - បង្ហាញពីអត្តសញ្ញាណអោយបានច្បាស់លាស់ និង
> ខ - បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់ លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរង នូវ

---

[72] វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៣។

[73] សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើតចំនួនទំព័រ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេច លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣ (ឯកសារ D269/2) (អង្គបុរេជំនុំជម្រះបានអនុញ្ញាត ដល់សហមេធាវីក្នុងការដាក់បណ្តឹងឧទ្ធរណ៍ ចំនួន៤៥ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ឬ ៩០ទំព័រជាភាសាខ្មែរ ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលដែលមានសេចក្តីជូនដំណឹងជាភាសាខ្មែរនូវឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើភាពអាចទទួលយកបាន (D269) និងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)។ ការបកប្រែជាភាសាខ្មែរនៃឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើភាពអាចទទួលយកបាន (D269) និងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) ត្រូវបានជូនដំណឹងនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩។ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩)។

ព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព ។

នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណី នោះមានភាពពិតប្រាកដ។

36. ដូចដែលអង្គបុរេជំនុំជម្រះ បានកត់សម្គាល់កន្លងមក[74] ធាតុផ្សំគតិយុត្តិដែលគ្រប់ដណ្ដប់លើវិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង រួមមានដូចតទៅ៖ (ក) អត្ថិភាពនៃទំនាក់ទំនងហេតុនិងផល រវាងឧក្រិដ្ឋកម្មនិងព្យសនកម្ម (ខ) ព្យសនកម្ម និង (គ) ភស្តុតាងនៃអត្តសញ្ញាណ។ វិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង ក៏បានចែងកំណត់ អំពីកម្រិតពាក់ព័ន្ធនៃភស្តុតាង ដែលធាតុផ្សំទាំងអស់នេះ ចាំបាច់ត្រូវកំណត់បង្ហាញ។ នៅក្នុងការត្រួតពិនិត្យរបស់ខ្លួន អង្គជំនុំជម្រះនឹងពិភាក្សាអំពី ចំណុចគតិយុត្តិជាក់លាក់ នៃធាតុផ្សំទាំងអស់នេះ និងកម្រិតនៃភស្តុតាងដែលពាក់ព័ន្ធ ក្នុងការវាយតម្លៃលើសារណា បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី។ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះនឹងផ្ដល់នូវការសង្កេតជាទូទៅដូចតទៅ។

37. ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះពិចារណាថា (១) កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក (២) ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក (៣) វិធាន ២១, ២៣, ២៣ស្ទួន ២៣ស្ទួនពីរ ២៣ស្ទួនបី ២៣ស្ទួនបួន និង ១១៤ នៃវិធានផ្ទៃក្នុង និង (៤) សេចក្ដីណែនាំអនុវត្ត ស្ដីពីការចូលរួមរបស់ជនរងគ្រោះ បង្កើតបានជាផ្នែកនៃបរិបទជាធរមាន ក្នុងការបកស្រាយលើលក្ខណៈវិនិច្ឆ័យ សម្រាប់ភាពអាចទទួលយកបាន ជាដើមបណ្ដឹងរដ្ឋប្បវេណី[75]។ គោលការណ៍ណែនាំអាចស្វែងរកបាន ពីគោលការណ៍ទូទៅស្ដីពីជនរងគ្រោះ នៅក្នុងច្បាប់អន្តរ

[74] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៥៧។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៥៧។

[75] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣១។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣១។

01672698



ជាតិ[76]។

38. ចំពោះអត្ថិភាពនៃទំនាក់ទំនងហេតុនិងផល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវបង្ហាញថា ព្យសនកម្មគឺជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ប្រឆាំងនឹងជនត្រូវចោទ[77]។ ទោះបីជាព្យសនកម្ម ចាំបាច់ត្រូវតែកើតឡើងផ្ទាល់ ចំពោះអ្នកដាក់ពាក្យសុំក្តី លក្ខខណ្ឌតម្រូវនៃព្យសនកម្ម ជាផលវិបាកផ្ទាល់នៃបទល្មើស មិនកម្រិតកំណត់ភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី តែចំពោះជនរងគ្រោះផ្ទាល់ឡើយ ប៉ុន្តែអាចរួមបញ្ចូលផងដែរនូវជនរងគ្រោះមិនផ្ទាល់ ដែលទទួលរងដោយផ្ទាល់នូវព្យសនកម្ម ដែលជាលទ្ធផលផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងទៅលើជនរងគ្រោះផ្ទាល់[78]។ ហេតុដូច្នេះ យុត្តិសាស្ត្ររបស់ អ.វ.ត.ក ទទួលស្គាល់ទាំងជនរងគ្រោះផ្ទាល់ និងជនរងគ្រោះមិនផ្ទាល់។ ជនរងគ្រោះផ្ទាល់ សំដៅលើ "ក្រុមបុគ្គលណាដែលសិទ្ធិរបស់ខ្លួន ត្រូវបានរំលោភបំពាន ឬទទួលរងការ

---

[76] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣២ យោងទៅ សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្មនិងការបំពានអំណាច សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ("គោលការណ៍សម្រាប់ជនរងគ្រោះ ឆ្នាំ១៩៨៥") និងគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ ស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណង សម្រាប់ជនរងគ្រោះដោយសារ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 60/147 ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ ឯកសាររបស់ អ.ស.ប A/RES/60/147 ("គោលការណ៍សម្រាប់ជនរងគ្រោះ ឆ្នាំ២០០៥"))។

[77] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៧១។

[78] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ("សំណុំរឿង ០០១") សាលដីកា ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ("សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១ (ឯកសារ F28)") កថាខណ្ឌ ៤១៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។

ប៉ះពាល់ ដែលបណ្តាលមកពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់"[79]។ ជនរងគ្រោះមិនផ្ទាល់គឺជាបុគ្គលទាំងឡាយណាដែល "ទទួលរងដោយផ្ទាល់នូវព្យសនកម្ម ដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តលើជនរងគ្រោះផ្ទាល់"[80]។

39. ចំពោះព្យសនកម្ម វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង ចែងថា ព្យសនកម្មចាំបាច់ត្រូវតែជាការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត[81]។ ការខូចខាតរាងកាយ "មានន័យថាការខូចខាតខាងជីវសាស្ត្រខាងសរីរាង្គ ឬខាងប្រព័ន្ធដំណើរការនៃសរីរាង្គ" និង "អាចជារបួសស្នាម កាលវិកលកម្ម ការខូចខាតទ្រង់ទ្រាយ មានជំងឺ ការបាត់បង់ ឬការមិនដំណើរការនៃ សរីរាង្គណាមួយ ឬមរណភាព"[82]។ ព្យសនកម្មខាងសម្ភារៈ "សំដៅដល់ការបាត់បង់តម្លៃជារូបិយ ដូចជាការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងស្រុង ឬមួយផ្នែក ឬការបាត់បង់ប្រាក់ចំណូលជាដើម"[83]។ ចុងក្រោយ ព្យសនកម្មខាងផ្លូវចិត្តអាច "រួមបញ្ចូលទាំងជំងឺផ្លូវចិត្ត ឬវិកលចរិត ដូចជាជំងឺបាក់ស្បាត"[84]។

40. ចំពោះលក្ខណៈតម្រូវ សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនទាំងអស់ ក្នុងការបង្ហាញច្បាស់លាស់ នូវអត្តសញ្ញាណរបស់ខ្លួន នាពេលកន្លងមក អង្គបុរេជំនុំជម្រះបានអនុម័តនូវ វិធានសាស្ត្របែបបទថែ[85] ដែលរួម

---

[79] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៦។

[80] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៥។ សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៨។

[81] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។

[82] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៥។

[83] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៦។ សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៥។

[84] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។ សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៥។

[85] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៧។

មានដូចជា ការទទួលយកជាភស្តុតាង នូវលិខិតបញ្ជាក់អត្តសញ្ញាណ ដែលចេញ ដោយចាស់ទុំក្នុងភូមិ ឬមេឃុំ[86]។

41. ចំពោះកម្រិតនៃភស្តុតាង ដែលត្រូវតែមានការបង្ហាញអំពីធាតុផ្សំខាងលើនេះ អនុលោមទៅតាមវិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ នៅពេលវាយតម្លៃលើសម្ភារៈ ដែលបានដាក់ជាផ្នែកនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវតែ "ជឿជាក់ថា អង្គហេតុដែលបានអះអាង ដើម្បីគាំទ្រដល់ពាក្យសុំនោះ មានភាពពិតប្រាកដ"[87]។

## V. អង្គសេចក្តី

42. ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើក្តី បន្ទាប់ពីប្រជុំពិភាក្សារួចហើយ អង្គជំនុំជម្រះមិនអាចរកបានសម្លេងភាគច្រើនលើសលប់នៃសម្លេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅដល់សេចក្តីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីឡើយ។ អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង មតិរបស់សមាជិកផ្សេងៗនៃអង្គបុរេជំនុំជម្រះ ត្រូវបានភ្ជាប់មកជាមួយសេចក្តីពិចារណាទាំងនេះ។

---

[86] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៥។

[87] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៤។

## VI. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

**ប្រកាសថា** អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រពីចៅក្រមចំនួនបួន សម្រាប់សេចក្តីសម្រេច ដោយផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីឡើយ។

អនុលោមតាមវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។ អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា។

**រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០២១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ធុល និង ចៅក្រម ហួត វុទ្ធី បានភ្ជាប់នូវមតិរបស់ខ្លួន។
ចៅក្រម Olivier BEAUVALLET និង ចៅក្រម Kang Jin BAIK បានភ្ជាប់នូវមតិរបស់ខ្លួន

## VII. មតិរបស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី

43. ទាក់ទិននឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមជាតិនៃ អបជ មានមតិបន្ថែមដូចតទៅៈ

44. ចៅក្រមជាតិនៃ អបជ បានពិចារណាឃើញថា ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការ មានសុពលភាពដូចគ្នា ហើយគប្បីបញ្ជូនសំណុំរឿង ០០៣ ដែល មាន មាស មុត ជាជនត្រូវចោទទៅតម្កល់ទុកនៅបណ្ណសារ នៃ អ.វ.ត.ក។

45. អនុលោមតាមវិធាន ២៣ ស្ទួននៃវិធានផ្ទៃក្នុង ចៅក្រមជាតិនៃ អបជ យល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**ទាំងអស់**គប្បីបដិសេធចោល។

46. ហេតុដូច្នេះ ចៅក្រមជាតិនៃ អបជ សម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០៣។

**រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១**

| | | |
|---|---|---|
| ចៅក្រម ប្រាក់ គីមសាន | ចៅក្រម ន័យ ថុល | ចៅក្រម ហួត វុទ្ធី |

## VIII. មតិរបស់ចៅក្រម OLIVIER BEAUVALLET និងចៅក្រម KANG JIN BAIK

### ក. មូលដ្ឋានទី ១៖ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងអង្គហេតុ ដោយគ្រាន់តែកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងដែនសមុទ្រ និងដែនកោះជិតឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យថាជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវពីទំនាក់ទំនងអនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង

### ១. សារណា

47. យោងតាមមូលដ្ឋានទី១ សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសារបានសម្រេចថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនង អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញដោយជនរងគ្រោះនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតាមទីតាំងដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងដែនទឹក និងដែនកោះជិតឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យ ខណៈខ្លួនគួរទទួលស្គាល់ថា (i) ជនរងគ្រោះនៃគោលនយោបាយ និងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ចំពោះ មាស មុត ថាត្រូវបានអនុវត្តនៅទូទាំងកម្ពុជាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម ("JCE")[88] (ii) ជនរងគ្រោះនៃក្រុមគោលដៅជាក់លាក់ដែលទទួលរងព្យសនកម្មរួមនៅក្រៅពីទីតាំងដូចបានកំណត់នៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន[89] និង (iii) ជនរងគ្រោះដែលជាប់ទាក់ទងដោយផ្ទាល់នឹងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលកើតឡើងនៅតំបន់ស្វយ័តកំពង់សោម[90]។

48. ចំណុចទី១ សហមេធាវីលើកឡើងថា នៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបានរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយផ្តោតតែទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងដែនទឹក និងដែនកោះជិតឆ្នេរនៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីមានការចោទប្រកាន់នានាថា មាស មុត បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិក៏ដោយ[91]។ សហមេធាវីអះអាងថា អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់នៅក្នុងសំណុំរឿង ០០២ ថា វិធាន ២៣ស្ទួន(១)(ខ) នៃវិធាន

---

[88] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២០-៣០។

[89] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣១-៣៧។

[90] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៨-៤០។

[91] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២០។

ផ្ទៃក្នុង តម្រូវយ៉ាងជាក់លាក់ឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញទំនាក់ទំនងរវាង "ព្យសនកម្ម" និង "ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" ដែលជា "ការកំណត់ប្រភេទបទល្មើសដែលត្រូវបានស៊ើបអង្កេត" ជាជាងអង្គហេតុដែលត្រូវបានស៊ើបអង្កេតផ្ទាល់[92]។ ហេតុនេះ ក្នុងករណីនៃការវាយប្រហារជាទ្រង់ទ្រាយធំ ឬ ជាលក្ខណៈប្រព័ន្ធប្រឆាំងនឹងប្រជាជន ជាពិសេស នៅពេលឧក្រិដ្ឋកម្ម និងគោលនយោបាយត្រូវបានអនុវត្តនៅទូទាំងកម្ពុជា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពុំចាំបាច់ភ្ជាប់ទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មតែមួយ ឬ ទីតាំងទាំងឡាយ ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនោះទេ[93]។

49. សហមេធាវីផ្តល់ទឡ្ហីករណ៍ថា ជំហររបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ អនុវត្តស្មើគ្នានៅក្នុងសំណុំរឿង ០០៣ ដោយសារ មាស មុត បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលមានគោលបំណងអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") នៅទូទាំងប្រទេសកម្ពុជា[94]។ សហមេធាវីអះអាងថា ដីកាបញ្ជូនទៅជំនុំជម្រះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "ពោរពេញដោយការចោទប្រកាន់ពីការចូលរួមរបស់ មាស មុត ក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលគ្របដណ្តប់លើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើសពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត" នៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះជិតឆ្នេរសមុទ្រនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងតួនាទីសំខាន់របស់គាត់នៅក្នុងការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា និងកម្មាភិបាលស្ថិតនៅក្នុងខេត្តក្រចេះ[95]។ ពួកគេអះអាងបន្ថែមទៀតថា សហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិត្រូវបានអនុវត្តតាមរយៈបណ្តាញក្រុមនៅថ្នាក់តំបន់ រួមទាំងតំបន់ទាំងឡាយក្រោមខ្សែបញ្ជារបស់ មាស មុត[96]។ ដើម្បីគាំទ្រដល់ការអះអាងទាំងនេះ សហមេធាវីបានយោងទៅការចោទប្រកាន់នានាអំពីការចូលរួមផុសផុលរបស់ មាស មុត នៅក្នុងការ

---

[92] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២០-២១ យោងទៅ សំណុំរឿង ០០២/១៩-០៩-២០០៧ ("សំណុំរឿង ០០២") សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 (សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីក្នុងសំណុំរឿង ០០២ (D404/2/4)") កថាខណ្ឌ ៤២។

[93] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២២ *យោងទៅ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីក្នុងសំណុំរឿង ០០២ (D404/2/4) កថាខណ្ឌ ៧២ ៧៨។

[94] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៣។

[95] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៧។

[96] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៣។

បង្កើតគោលនយោបាយជាតិ[97] និងការឆ្លើយតបជាញឹកញាប់ជាមួយ "ថ្នាក់លើ" នៃ ប.ក.ក រួមទាំង ប៉ុល ពត[98] ព្រមទាំង "ការចូលរួមចំណែកជាដុំកំភួន" ចំពោះគោលនយោបាយជាតិទាំងបួននៅថ្នាក់តំបន់[99] រួមទាំង តាមរយៈការកំណត់អត្តសញ្ញាណ "ខ្មាំង ឬ ជនក្បត់" ក្នុងចំណោមជួរកងទ័ពបដិវត្តន៍កម្ពុជា ("ក.ប .ក") និងការបោសសម្អាត "សមាសធាតុមិនពេញចិត្ត"[100]។ សហមេធាវីសង្កេតឃើញបន្ថែមទៀតថា យោងតាម "តួនាទីដែលកាន់តែឡើងឋានៈខ្ពស់ទៅៗ" របស់ មាស មុត ដែលសហចៅក្រមស៊ើបអង្កេតកំណត់ថាជា "កម្រិតលេចធ្លោជាង អោ អាន" ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានសន្និដ្ឋានថា កម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត "គឺពិតជាលើសអំពើរបស់ អោ អាន អ៊ឹម ចែម និង កាំង ហ្គេកអ៊ាវ ហៅ ឌុច"[101]។

50. ហេតុនេះ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយផ្តោតតែទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះជិតឆ្នេរសមុទ្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីកំណត់អំពីភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី "ទោះបីមានការបង្ហាញយ៉ាងច្បាស់ប្រចក្សអំពី "លក្ខណៈរួម" នៃការទទួលខុសត្រូវរបស់ មាស មុត ក៏ដោយ" ហើយផ្ទុយទៅវិញគួរតែបានពិចារណាទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅខាងក្រៅតំបន់ទាំងនោះ ដែលវាក៏បានបង្កើតជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែល មាស មុត ត្រូវបានចោទប្រកាន់ថាបានចូលរួម

---

[97] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២២ យោងទៅ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ (D1) កថាខណ្ឌ ៨៨។

[98] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៣ យោងទៅ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ (D1) កថាខណ្ឌ ៩២-៩៣។

[99] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៥ យោងទៅ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ (D1) កថាខណ្ឌ ៣៣-៣៤។ សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120 ("ដីកាសន្និដ្ឋានឲ្យស៊ើបសួរបន្ថែម ("ឯកសារ D120") កថាខណ្ឌ ២០-២៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267)) កថាខណ្ឌ ១៧១, ៥៦៦-៥៦៨, ៥៧០។

[100] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៦ យោងទៅ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ (ឯកសារ D1) កថាខណ្ឌ ៤, ៣៣។

[101] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៤ យោងទៅ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267) កថាខណ្ឌ ៤៦០, ៤៦១។

នោះ[102]។ ដូច្នេះ សហមេធាវីស្នើឱ្យអង្គបុរេជំនុំជម្រះទទួលយកម្ចាស់បណ្ដឹងឧទ្ធរណ៍នៅក្នុងឧបសម្ព័ន្ធ គ និង ឃ នៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ដែលបានទទួលរងព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់ពីការអនុវត្តសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិនេះ[103]។

51. ចំណុចទី២ សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយសារបានកម្រិតវិសាលភាពភូមិសាស្ត្រនៃការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះតែជនរងគ្រោះដែលរស់នៅក្នុងតំបន់ដែលមាស មុត មានសិទ្ធិគ្រប់គ្រងផ្នែករដ្ឋបាលដោយសារសមាជិកនៃក្រុម និងសហគមន៍គោលដៅជាក់លាក់ នៅក្រៅតំបន់ទាំងនេះក៏ទទួលរងព្យសនកម្មរួមដូចគ្នា[104]។ សហមេធាវីអះអាងថា អង្គបុរេជំនុំជម្រះបានទទួលស្គាល់នូវ "ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាព" លាតសន្ធឹងដល់សមាជិកនៃក្រុម និងសហគមន៍ដែលត្រូវបានធ្វើទុក្ខបុកម្នេញដូចគ្នា នៅពេលដែលឧក្រិដ្ឋកម្មឃោរឃៅទាំងនេះត្រូវបានចោទប្រកាន់ ដោយពុំមានលក្ខខណ្ឌតម្រូវនៃភាពជិតគ្នាផ្នែករូបរាងកាយរវាងសមាជិកផងនោះ[105]។ សហមេធាវីចោទប្រកាន់បន្ថែមថា ការគាំទ្រដល់គោលការណ៍នៃ "ការខូចខាតជាសមូហភាព" របស់ អ.វ.ត.ក មានលក្ខណៈស្រដៀងគ្នាជាមួយការអនុវត្តជាអន្តរជាតិ[106] ដោយសារសញ្ញាណនេះត្រូវបាន

---

[102] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៨។

[103] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៩-៣០ (សហមេធាវីយោងទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ដែលបានទទួលរងព្យសនកម្មជាផលវិបាកនៃគោលនយោបាយទាំងបួន ដែលត្រូវបានអនុវត្តដើម្បីពន្លឿនការអនុវត្តសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ រួមមាន កែវ ធារី (11-VSS-00030), សំ ស៊ីថា (13-VSS-00370), សេង យាង (15-VSS-00138), សេ សុខន (17-VSS-00021), តន់ សុខ (11-VSS-00120)។ យោងទៅ សំណុំរឿង ០០៣ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មដោយសារការកំណត់គោលដៅ ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/3) ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3.2.3 ("ឧបសម្ព័ន្ធ គ នៃបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/3.2.3)")។ សំណុំរឿង ០០៣ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មដោយសារការកំណត់គោលដៅ ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/3) ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3.2.5 ("ឧបសម្ព័ន្ធ ឃ នៃបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/3.2.5)")។

[104] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣១។

[105] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣២ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៣-៩៣។

[106] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៣។

ទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ[107] គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៨៥ និងឆ្នាំ២០០៥[108] និងស្ថាប័នសិទ្ធិមនុស្សជាច្រើនទៀត ដូចជាគណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក និងតុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក[109]។

52. សហមេធាវីសូមរំលឹកថា មាស មុត ទទួលខុសត្រូវចំពោះការវាយប្រហារនៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យ ដែលមានគោលដៅទៅលើក្រុម ឬសហគមន៍ជាក់លាក់[110] និងអះអាងថា យោងតាមសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ "ការសន្មតជាមុនពី

---

[107] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៣ យោងទៅ តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សំណុំរឿងលេខ ICC-01/04-01/06-1432 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការចូលរួមរបស់ជនរងគ្រោះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

[108] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៣ *ដកស្រង់ពី សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាច* សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤០/៣០ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឯកសារ អ.ស.ប A/RES/40/34 ឧបសម្ព័ន្ធ ក.១។ គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៦០/១៤៧ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ ឯកសាររបស់ អ.ស.ប A/RES/60/147 បុព្វកថា។

[109] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៣ យោងទៅ គណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក *មជ្ឈមណ្ឌលអភិវឌ្ឍន៍សិទ្ធិជនជាតិភាគតិច (កេនយ៉ា) និង ក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ តាងនាមឱ្យក្រុមប្រឹក្សាសុខុមាលភាពអង់ឌ្វរ័ស ទល់នឹង ប្រទេសកេនយ៉ា* ឯកសារលេខ No. 276/03 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ២៥៨។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ *យោបល់ទូទៅលេខ ២១៖ សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការចូលរួមក្នុងជីវភាពខាងវប្បធម៌*សម័យប្រជុំលើកទី ៤៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ អប លេខ.ស. E/C. 12/GC/21 កថាខណ្ឌ ៣៧។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក *ករណីជនជាតិភាគតិចគិច្វា (Kichwa) នៃអម្បូរ Sarayaku ទល់នឹង ប្រទេសអេក្វាឌ័រ* សាលក្រម (អង្គសេចក្តី និងសំណង) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ស៊េរី គ លេខ ២៤៥ កថាខណ្ឌ ២៣១-២៣២, ២៨៤។

[110] យោងតាមសហមេធាវី ក្រុម ឬសហគមន៍ផ្សេងៗដែលត្រូវបានកំណត់គោលដៅ រួមមាន ជនជាតិវៀតណាម និងថៃ "ប្រជាជនថ្មី" អតីតអ្នករាជការសាធារណរដ្ឋខ្មែរ និងអ្នកក្រោមបង្គាប់ លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានគេគិតថាក្បត់ ខ្មែរក្រោម និង "គីញ" របស់សេអ៊ីអា និងកាហ្សេបេ។ សូមមើល បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៤ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D360) កថាខណ្ឌ ១៩០, ២៧៣, ២៧៧, ២៧៩, ៣៤៩៣៥០-, ៣៩០, ៤១៣, ៤១៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ (D1) កថាខណ្ឌ ៥៣៥៩ ,៥៤--៦០។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (D120) កថាខណ្ឌ ៦។

ការខូចខាតជាសម្ភូហភាព ដែលកើតចេញពីព្យសនកម្មដែលទទួលរងគ្រោះផ្ទាល់នៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យ លាតសន្ធឹងដល់សមាជិកគ្រប់រូបនៃក្រុមមនុស្ស ឬសហគមន៍គោលដៅជាក់លាក់ទាំងនេះ ដោយមិនគិតដល់ទីកន្លែងរបស់ពួកគេ”[111]។ ពួកគេអះអាងថា ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់នូវគោលការណ៍នៃព្យសនកម្មជាសម្ភូហភាពនៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបានក្តី តែគាត់ “ដាក់លក្ខខណ្ឌដែលមានកំហុសថាសមាជិកដែលរស់នៅក្នុងក្រុម ឬសហគមន៍គោលដៅតែមួយ ត្រូវមានទីតាំងស្ថិតនៅក្នុងនៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យ”[112]។

53. ហេតុដូច្នេះ សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការបដិសេធដីកាសម្រេចស្តីពីភាពអាចទទួលយកបាន និងទទួលយកអ្នកដាក់ពាក្យសុំនៅក្នុងឧបសម្ព័ន្ធ គ ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបាន ផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីបង្ហាញថា ពួកគាត់ជាសមាជិកនៅក្នុងក្រុមដែលត្រូវបានចាត់ទុកជាគោលដៅជាក់លាក់មួយឬច្រើន ឬសហគមន៍ដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងសេចក្តីសន្និដ្ឋាន[113]។

54. ចំណុចទីបី សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយសារសម្រេចមិនទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មដោយសារគោលនយោបាយ និងឧក្រិដ្ឋកម្មដែលជាប់ទាក់ទងនឹង មាស មុត នៅក្នុងតំបន់ស្វយ័តកំពង់សោម។ ដោយឡែកនៅក្នុងដីកាសម្រេចលើភាពអាចទទួលយកបាន គាត់គិតពិចារណាអំពីការទទួលយកអ្នកដាក់ពាក្យសុំដែលការខូចខាតដូចបានចោទប្រកាន់របស់ខ្លួនពុំកើតចេញពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង ជាពិសេស

---

[111] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៤។

[112] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៥ យោងទៅ ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន (D269) កថាខណ្ឌ ៣៣។

[113] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៦-៣៧ (សហមេធាវីយោងទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ដែលបានទទួលរងព្យសនកម្មជាផលវិបាកដោយសារជាសមាជិកនៃក្រុម ឬសហគមន៍ដែលត្រូវបានចាត់ទុកជាគោលដៅ រួមមាន ឡេង ណាន (11-VSS-00070), វ៉ែន វ៉ន (11-VSS-00276), ឈន់ យាន (11-VSS-00143), ថេង វណ្ណៈ (15-VSS-00139), ប៉ែន ហឿន (11-VSS-00094), ប៉ាង ស្រី (13-VSS-00730), ទូច ឈី (17-VSS-00026), ម៉ក វណ្ណា (13-VSS-00734), ស៊ុង ស៊ាង (15-VSS-00137), ហែម ចូត (15-VSS-00136), ណន យ៉េម (13-VSS-00601), ម៉ី សាវឿន (11-VSS-00042), ជា ម៉ារី (17-VSS-00001), យ៉ាន់ ញ៉ (11-VSS-00262), ឡុង ផាន (11-VSS-00182), សេក ផល្លា (14-VSS-00163))។ ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D269/3.2.2)”)។

នៅតាមទីតាំងដូចបានកំណត់នៅក្នុងសេចក្ដីសន្និដ្ឋាន ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[114]។ សហមេធាវីតវ៉ាថា ដោយសារតួនាទីរបស់ មាស មុត ជាលេខាតំបន់ស្វយ័តកំពង់សោម និងដោយសារសិទ្ធិអំណាចផ្នែករដ្ឋបាលលើតំបន់នោះ[115] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដូចបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ខ នៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ដែលទទួលរងព្យសនកម្មនៅក្នុងតំបន់នោះ ទោះបីជាមិនមែននៅទីតាំងជាក់លាក់ដូចបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសារលទ្ធផលនៃឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ប្រឆាំង មាស មុត គួរតែប្រកាសទទួលស្គាល់ ដោយសារ "ទីតាំងនៃព្យសនកម្មរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍[ទាំងនេះ]នៅក្នុងតំបន់ និងទីតាំងឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុង[ដីកាបញ្ជូនរឿងទៅជំនុំជម្រះ] របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្ដល់នូវទំនាក់ទំនងបន្ថែមរវាងព្យសនកម្មរបស់ពួកគេជាមួយសកម្មភាពឧក្រិដ្ឋកម្មរបស់ [មាស] មុត"[116]។

## ២. ការពិភាក្សា

### ក. ច្បាប់ជាធរមាន

55. ស្ដីអំពីគោលបំណងនៃបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី វិធាន ២៣(១) នៃវិធានផ្ទៃក្នុងចែងថា៖

> គោលបំណងនៃបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺដើម្បី៖
>
> ក-ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់ ។ និង

[114] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៨ យោងទៅ ដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន (D269/3.2.3)។

[115] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៩។

[116] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៤០ *យោង* គង់ សំណាង (11-VSS-00301), ព្រំ សាម៉ុន (14-VSS-00017), អន ដារ៉ារុត (17-VSS-00043), ហេង ណារី (14-VSS-00014), ម៉ៅ សុផល (14-VSS-00012) *នៅក្នុង*សំណុំរឿង ០០៣ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលរងការខូចខាតដោយអំពើនៅទីតាំងឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D269/3) ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3.2.2។

ខ-ទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាន ២៣ *ស្ទួនបួន* ។

56. ឆ្លើយតបទៅនឹងពាក្យសុំ និងការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី វិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុងចែងថា៖

ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវ៖

ក - បង្ហាញពីអត្តសញ្ញាណអោយបានច្បាស់លាស់ និង

ខ - បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។

នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

57. វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងអំពីក្របខណ្ឌនៃការបកស្រាយចំពោះវិធានផ្ទៃក្នុងដែលបានលើកឡើងខាងលើ និងចែងនៅត្រង់ផ្នែកពាក់ព័ន្ធថា៖

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង [...] ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។

<u>ខ. មូលដ្ឋានទី ១(១)</u>

58. វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋ

ប្បវេណី និងចែងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ "បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទថា ខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត"[117]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសង្កេតឃើញថា វិធានផ្ទៃក្នុងនេះតម្រូវឱ្យទំនាក់ទំនងរវាង "បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់" និង "ព្យសនកម្ម" ដែលអ្នកដាក់ពាក្យសុំបានទទួលរង[118]។ អង្គបុរេជំនុំជម្រះធ្លាប់បានសន្និដ្ឋានថា ទោះបី "វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុងមិនបានទាមទារឱ្យមានទំនាក់ទំនងហេតុផលរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មណាមួយដែលបានស៊ើបអង្កេតនោះឡើយ គឺវាតម្រូវឱ្យមានទំនាក់ទំនងហេតុនិងផល រវាងព្យសនកម្មនិងឧក្រិដ្ឋកម្មណាមួយដែលបានចោទប្រកាន់ប៉ុណ្ណោះ"[119]។ ហេតុនេះ ព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ត្រូវតែមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីអាចយកមកពិចារណាពីភាពអាចទទួលយកបាននៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[120]។

59. អត្ថន័យនៃវិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានយកមកបញ្ជាក់បន្ថែមទៀតដោយអង្គបុរេជំនុំជម្រះ។ ទោះបីកត់សម្គាល់ពីយោបល់ជំទាស់ជាក់ស្តែងមួយផ្នែកនៅក្នុងសំណុំរឿង ០០២ ក្តី[121] តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិសង្កេតឃើញថា៖ "អង្គបុរេជំនុំជម្រះពិចារណាថា វត្ថុបំណង និងគោលបំណងនៃវិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុង មិនមែនបង្កើតឡើងសម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នោះទេ។ ប៉ុន្តែវិធាននេះ បង្កើតឡើងសម្រាប់កំណត់លក្ខណៈវិនិច្ឆ័យក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

---

[117] វិធាន ២៣*ស្ទួន* (ខ)(១)នៃវិធានផ្ទៃក្នុង។

[118] វិធាន ២៣*ស្ទួន* (ខ)(១)នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២។

[119] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២, ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២, ៧១។

[120] សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៥៦។

[121] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) មតិយោបល់ [ជំទាស់] ដោយឡែក និងមួយផ្នែករបស់ចៅក្រម Catherine MARCHI-UHEL ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) មតិយោបល់របស់ចៅក្រម Catherine MARCHI-UHEL") កថាខណ្ឌ ៣-៥។

ប្បវេណី"[122]។ នៅក្នុងបរិបទនៃសំណុំរឿង ០០២ ដែលមានជនជាប់ចោទច្រើននាក់ត្រូវបានផ្ដើយដាក់នោះ អង្គជំនុំជម្រះបានសង្កេតឃើញថា ទោះបី "អង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុទាំងនេះ [...] រួមបញ្ចូលនូវឧក្រិដ្ឋកម្ម [...] ជនត្រូវចោទបានធ្វើឡើងរួមគ្នា ក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្ម ព្រមទាំងរួមបញ្ចូលឧក្រិដ្ឋកម្មដទៃទៀតដែលបានធ្វើឡើងប្រឆាំងប្រជាជន និង "នៅទូទាំងប្រទេស""[123]។ ដូចបានកត់សម្គាល់ដោយអង្គបុរេជំនុំជម្រះគឺថា "ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ជាពិសេសក្នុងសំណុំរឿង ០០២ គឺស្ថិតក្នុងស្ថានភាពខុសគ្នា ពីជនរងគ្រោះនៅចំពោះមុខតុលាការក្នុងស្រុក និងសូម្បីតែជនរងគ្រោះនៅ អ.វ.ត.ក ក្នុងសំណុំរឿង ០០១ ក៏មានស្ថានភាពខុសគ្នាដែរ[124]"។ ហេតុនេះ នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានសម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមិនចាំបាច់ត្រូវតែភ្ជាប់ទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មនានាដែលបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយទេ "ដោយសារឧក្រិដ្ឋកម្ម និងគោលនយោបាយបក្សកុម្មុយនីស្តជាមូលដ្ឋានបង្កើតជាមូលដ្ឋាននៃការចោទប្រកាន់ដែលត្រូវបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជាទាំងមូល"[125] ដោយមានបទល្មើសនានា "រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពានដល់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦"[126]។

60. នៅក្នុងករណីនេះ សហមេធាវីយោងយ៉ាងទូលំទូលាយទៅសេចក្ដីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០២ ក្ដី[127]។ ទោះបីជាយ៉ាងនេះក្ដី សហចៅក្រមអន្តរជាតិសង្កេតឃើញថា ជនជាប់

---

[122] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦២។

[123] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២។

[124] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦៩។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦៩។

[125] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧២។

[126] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧១។

[127] បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២១-២២។

ចោទជាច្រើននាក់ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពីឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្ត*ទូទាំង*ប្រទេសកម្ពុជា នៅក្នុងសំណុំរឿង ០០២[128]។ ផ្ទុយពីសំណុំរឿង ០០៣ ដែល មាស មុត ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរសមុទ្រនៃកម្ពុជាប្រជាធិបតេយ្យ និងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងបរិបទនៃការបោសសម្អាតកងពលធំលេខ ១១៧, ១៦៤, ៣១០, និង ៥០២ តែប៉ុណ្ណោះ[129]។ ជាក់ស្ដែង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានកំណត់និយមន័យ និងកម្រិតច្បាស់លាស់អំពីវិសាលភាពនៃរឿងក្តី និងភូមិសាស្ត្រនៃរឿងក្តីដូចតទៅ៖ "[មាស] មុត គឺជាបុគ្គលចំបងទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយ ប.ក.ក *នៅក្នុងតំបន់ក្រោមសិទ្ធិអំណាចគ្រប់គ្រងរបស់ខ្លួន*"[130] និង "នៅពេលមានការណែនាំ [ទាក់ទិននឹងការបោសសំអាតកងពលធំ នៅក្នុងគាំទ្រដល់គោលនយោបាយកំណត់គោលដៅរបស់ ប.ក.ក] នៅខាងក្រៅតំបន់នោះ"[131] ដែលជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម ជាមួយ សុន សេន, ស៊ូ ម៉េត, តាម៉ុក និងកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលមានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[132]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិពិចារណាឃើញថា កាលៈទេសៈទាំងឡាយដែលបានកំណត់ដោយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ពុំកើតមានជាទូទៅនៅក្នុងរឿងក្តីនេះទេ ហេតុដូច្នេះ យល់ឃើញថា ទស្សនករណ៍ពាក់ព័ន្ធនឹងការសម្រេចក្នុងសំណុំរឿង ០០២ របស់សហមេធាវី ពុំមានចំណុចពាក់ព័ន្ធគ្នានោះទេ។

61. ជាងនេះទៅទៀត សហមេធាវីជំទាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីនៅទូទាំងប្រទេសកម្ពុជាគួរត្រូវបានទទួលស្គាល់ និងបានលើកយោងម្តងហើយម្តងទៀតទៅដល់ការចោទប្រកាន់ ដែលបានធ្វើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដើម្បីគាំទ្រដល់ការ

---

128 *សូមមើលឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧៤-៧៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧៤-៧៥។

129 *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២៥៦ ២៦៤។-*សូមមើលផងដែរ* ដីកាសម្រេចលើភាពអាចទទួលយកបាន )D269) កថាខណ្ឌ ៣៦៣៧។-

130 *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៦៥ (ការគូសបញ្ជាក់បន្ថែម)។

131 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៦៨។

132 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៦២។

អះអាងនេះ[133]។ ចៅក្រមអន្តរជាតិរំលឹកថា នៅដំណាក់កាលនៃការចេញដីកាដំណោះស្រាយ ឯកសារដែលមានអំណាចអាជ្ញាបញ្ញា ដែលបង្កើតវិសាលភាពនៃការពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង គឺដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនដីកាពីមុនៗដែលចេញដោយការិយាល័យសហព្រះរាជអាជ្ញានោះឡើយ[134]។ នៅក្នុងន័យនេះ ចៅក្រមអន្តរជាតិពិចារណាឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញចំណងទាក់ទងហេតុ និងផល ទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងការពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង ហើយមិនមែនចំពោះ “(១) វិសាលភាពទូលំទូលាយនៃកិច្ចស៊ើបសួរ (២) អង្គហេតុដែលត្រូវបានបើកការស៊ើបអង្កេតរួចហើយ ឬ (៣) អង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរនោះទេ”[135]។

62. ហេតុនេះ វាជាការសន្និដ្ឋានដ៏សមហេតុសមផលថា នៅក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលនេះ ដើម្បីអាចឱ្យទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីបាន នោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញថា ខ្លួនបានទទួលផលវិបាកដោយផ្ទាល់ពីបទល្មើសយ៉ាងហោចណាស់មួយ ដែលបានចោទប្រកាន់ថាខ្លួនពិតជាបានទទួលរងព្យសនកម្មផ្លូវកាយ សម្ភារៈ ឬ ផ្លូវចិត្ត ជាមូលដ្ឋាននៃការទាមទារសំណងផ្លូវចិត្ត និងសំណងជាសមូហភាព[136]។

63. ចៅក្រមអន្តរជាតិសង្កេតឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះចោទប្រកាន់ មាស មុត ពីបទឧក្រិដ្ឋជាច្រើន ដែលបានប្រព្រឹត្តនៅក្នុងតំបន់ភូមិសាស្ត្រមានកម្រិត[137] ហើយដីកាសម្រេចដែលរងការ

---

[133] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២៣, ២៥-២៦។

[134] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៥៩។ សូមមើលផងដែរ វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង (“សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ”)។

[135] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៥៩ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) មតិយោបល់របស់ចៅក្រម Catherine MARCHI-UHEL កថាខណ្ឌ ៣៤។

[136] វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៦០។

[137] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) ទំព័រ ៤២២-៤៣១។

ជំទាស់ កម្រិតយ៉ាងសមស្របនូវភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមតែអ្នក "ដែលបានទទួលរងព្យសនកម្មនៅក្នុងតំបន់កំពង់សោម ឬនៅក្នុងដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ រវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩" ឬ "នៅក្នុងបរិបទនៃការបោសសម្អាតកងពល ១១៧ កងពល១៦៤ កងពល៣១០ និងកងពល ៥០២" ស្របតាមបទចោទជាក់លាក់ទាំងនេះ[138]។ ហេតុដូច្នេះផ្ទុយពីការចោទប្រកាន់របស់សហមេធាវី[139] ចៅក្រមអន្តរជាតិយល់ឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងព្យសនកម្ម ដែលពុំកើតចេញពីឧក្រិដ្ឋកម្មដែលបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំបំពេញលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល នៅក្រោមវិធាន ២៣ស្ទួន(១)(ខ) នោះទេ។

64. ជាចុងក្រោយ ចៅក្រមអន្តរជាតិពិចារណាឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនអាចទទួលយកបានភាគច្រើន ដែលលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហមេធាវី និងអ្នកមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ គ (ក្រុមគោលដៅ)[140] និងឧបសម្ព័ន្ធ ឃ (សហឧក្រិដ្ឋកម្មរួម) នៃបណ្តឹងឧទ្ធរណ៍របស់ពួកគេ[141] អាចទទួលរងពីអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំកើតឡើងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិយល់ឃើញថា ព្រឹត្តិការណ៍ភាគច្រើនដែលបានពិពណ៌នា ពុំមែនជាឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០៣ ដូចដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសអង្គច្បាប់ ដោយសារតែការកម្រិតវិសាលភាពភូមិសាស្ត្រ និងរឿងក្តី និងដោយការពិចារណាតែទៅលើជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅតំបន់កំពង់សោម ឬនៅក្នុងដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ឬ នៅក្នុងបរិបទនៃការបោសសម្អាតកងពល១១៧ កងពល១៦៤ កងពល៣១០ និងកងពល៥០២ ដោយការសម្រេចច្រានចោលអ្នកដាក់ពាក្យសុំដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ គ និង ឃ នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវី ដែលពុំជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ នៅក្នុងបរិបទដូចបានរៀបរាប់ខាងលើនោះឡើយ។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិរម្លឹកឡើងវិញថា ការពង្រីកបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទ ហួសពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងទីតាំងភូមិសាស្ត្រដូចបានកំណត់នោះ

---

[138] ដីកាសម្រេចលើភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D269) កថាខណ្ឌ ៣៦-៣៧។

[139] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ២០-២៨, ៣០។

[140] ឧបសម្ព័ន្ធ គ ភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3.2.3)។

[141] ឧបសម្ព័ន្ធ ឃ ភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3.2.5)។

គឺពុំសមស្រប និងពុំត្រឹមត្រូវ ដែលដាកចេញពីលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល អនុលោមតាមវិធាន ២៣ *ស្ទួននៃវិធានផ្ទៃក្នុង*[142]។

65. ទោះបីយ៉ាងណាក៏ដោយ បន្ទាប់ពីបានពិនិត្យមើលទៅលើឧបសម្ព័ន្ធនានានៃបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីដែលបានបញ្ជាក់ជូនខាងលើនោះរួចមក ចៅក្រមអន្តរជាតិយល់ឃើញថា មានកំហុសមួយទាក់ទិនទៅនឹងអ្នកដាក់ពាក្យសុំ ឡុង រ៉ន (11-VSS-00138) ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាននៅក្នុងដីកាសម្រេចលើភាពអាចទទួលយកបាន ប៉ុន្តែបង/ប្អូនប្រុសរបស់គាត់គឺជាជនរងគ្រោះនៃការបោសសំអាតក្នុងកងពលធំ ៣១០ ដែលជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌដែល មាស មុត ត្រូវបញ្ជូនទៅជំនុំជម្រះ។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ នៅក្នុងការសម្រេចរបស់ខ្លួនលើភាពអាចទទួលយកបាន ទាក់ទិននឹងអ្នកដាក់ពាក្យសុំរូបនេះ ដែលជាក់ស្ដែងបំពេញបាននូវលក្ខខណ្ឌតម្រូវពីទំនាក់ទំនង អនុលោមតាមវិធាន ២៣ស្ទួន នៃវិធានផ្ទៃក្នុង ហើយគួរតែត្រូវបានទទួលស្គាល់ ដោយសំអាងលើហេតុផលដែលបានបញ្ជាក់ជូននៅក្នុងឧបសម្ព័ន្ធ ១ នៃមតិយោបល់នេះ។ អាស្រ័យហេតុនេះ សម្រេចតម្កល់មូលដ្ឋានទី១(១) ទាក់ទិននឹង ឡុង រ៉ន (11-VSS-00138) និងច្រានចោលអ្នកដាក់ពាក្យសុំដែលនៅសេសសល់។

## គ. មូលដ្ឋានទី១(២)

66. អនុលោមតាមវិធាន ២៣ស្ទួន(១)(ខ) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវ "បង្ហាញ [...] ថា ខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត"[143]។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាលើលក្ខណៈ និងវិសាលភាពនៃព្យសនកម្មផ្លូវចិត្ត ដែលបានទទួលរងនៅក្នុងបរិបទនៃអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំ ប្រព្រឹត្តឡើងនៅទូទាំងប្រទេសកម្ពុជា[144] ហើយបានពង្រីកសច្ចធារណ៍នៃព្យសនកម្មផ្លូវចិត្ត រហូតដល់ជនរងគ្រោះដោយប្រយោល ដែលពុំមានទំនាក់

---

[142] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៥៥។

[143] វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។

[144] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨១។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨១។

ទំនងគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ ប៉ុន្តែ ដែលជាផ្នែកមួយនៃក្រុមគោលដៅតែមួយ[145]។ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា៖

> ការត្រឹមតែដឹងពីជោគវាសនារបស់មនុស្សណាម្នាក់ ដែលជាជនរងគ្រោះផ្ទាល់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង ដោយសារការអនុវត្តគោលនយោបាយរហូតមានការប៉ះពាល់យ៉ាងដូច្នេះ វាលើសពីការរំខានផ្លូវចិត្តទៅទៀតចំពោះមនុស្ស ដែលមានសភាពផ្លូវចិត្តធម្មតា។ ការរំខានបែបនេះមិនត្រឹមតែកើតចេញពីការបានឃើញផ្ទាល់ភ្នែក នូវការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះប៉ុណ្ណោះទេ តែក៏កើតចេញពីការគម្រាមកំហែងដែលកើតមានជាបន្តបន្ទាប់ ដោយសារព្រឹត្តិការណ៍ទាំងនេះអាចនឹងបង្កជាការភ័យខ្លាចដល់អ្នកដទៃទៀតដែលថា ពួកគេនឹងជួបនូវជោគវាសនាបែបនេះដែរ ដោយសារពួកគេស្ថិតនៅក្នុងក្រុម ឬ សហគមន៍តែមួយ ជាមួយជនរងគ្រោះផ្ទាល់នៃបទឧក្រិដ្ឋណាមួយ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការអនុវត្តគោលនយោបាយរបស់ ប.ក .ក[146]។

67. តាមរយៈការសង្កេតបែបនេះ អង្គជំនុំជម្រះបានសម្រេចថា "ចំពោះអ្នកដាក់ពាក្យសុំទាំងឡាយណាដែលអះអាងថា បានទទួលរងព្យសនកម្មផ្លូវចិត្តដែលមិនមានភាពជិតស្និទ្ធជាមួយជនរងគ្រោះដោយផ្ទាល់នោះ អង្គបុរេជំនុំជម្រះត្រូវអនុវត្តតាមការសន្មតថា ជាព្យសនកម្មរួម" នៅក្នុងការវាយតម្លៃរបស់ខ្លួនចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[147]។

68. នៅក្នុងរឿងក្តីនេះ ចៅក្រមអន្តរជាតិបញ្ជាក់ថា ជនរងគ្រោះដោយប្រយោល អាចបង្ហាញព្យសនកម្មផ្លូវចិត្ត ទោះបីជាពុំមានទំនាក់ទំនងគ្រួសារជាមួយជនរងគ្រោះដោយផ្ទាល់ តាមរយៈសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមគោលដៅ ឬសហគមន៍តែមួយក៏ដោយ[148]។ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមពិត បានអនុវត្តតាមវិធីសាស្ត្រនេះ ដូចបានសន្និដ្ឋាននៅក្នុងផ្នែកពាក់ព័ន្ធនៃដីកា

---

[145] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣-៩៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣-៩៣។

[146] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៦។

[147] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៣។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៣។

[148] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៦៤។

សម្រេចលើភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី៖

> ព្យសនកម្មខាងផ្លូវចិត្ត គឺរួមបញ្ចូលទាំងព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់ទទួលរងដោយផ្ទាល់ពីឧក្រិដ្ឋ ឬជាព្យសនកម្មដែលជនរងគ្រោះមិនផ្ទាល់ បានទទួលរងដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់ ឬ ដោយសារព្យសនកម្មដែលជនរងគ្រោះផ្ទាល់បានទទួលរង។ *ជនរងគ្រោះមិនផ្ទាល់អាចរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងជាគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឱ្យតែពួកគាត់ជាសមាជិកនៅក្រុមគោលដៅតែមួយ ឬ ក្នុងសហគមន៍តែមួយ ឬ ប្រសិនបើជនរងគ្រោះមិនផ្ទាល់បានទទួលរងព្យសនកម្មដោយសារតែជនរងគ្រោះផ្ទាល់បានទទួលរង*[149]។

69. ផ្អែកលើមូលដ្ឋាននេះ សហមេធាវីចោទប្រកាន់ថា "ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាព ដែលកើតចេញពីព្យសនកម្ម ដែលទទួលរងដោយជនរងគ្រោះផ្ទាល់បានទទួលរង នៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ បានពង្រីកវហូតដល់សមាជិកទាំងអស់នៃក្រុម ឬសហគមន៍ដែលជាគោលដៅជាក់លាក់ ដោយមិនគិតអំពីទីកន្លែងរបស់ពួកគេឡើយ"[150] ទោះបីជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិសូមរម្លឹកថា វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងទាមទារឱ្យមានទំនាក់ទំនងរវាង*ព្យសនកម្ម* និង*ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់*[151] រួមទាំងទំនាក់ទំនងជាមួយជនរងគ្រោះដោយប្រយោលផងដែរ។

70. ផ្ទុយពីសំណុំរឿង ០០២ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹង មាស មុត បានកម្រិតត្រឹមវិសាលភាពភូមិសាស្ត្រ និងរឿងក្តីនៃតំបន់កំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការបោសសម្អាតកងពល១១៧ កងពល១៦៤ កងពល៣១០ និងកងពល៥០២"[152]។ ជាពិសេស ដីកាបញ្ជូនរឿងទៅជំនុំជម្រះរៀបរាប់ពីការកំណត់គោលដៅទៅលើក្រុមជាក់លាក់ដូចខាងក្រោម៖

---

[149] ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D269) កថាខណ្ឌ ៣៣ (គូសបញ្ជាក់បន្ថែម)។

[150] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៥។

[151] វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង។

[152] *សូមមើល*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) ទំព័រ ៤២២-៤៣១។ សូមមើលផងដែរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ២១៧-៤៥៥។

ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ [មាស] មុត [...] និងកម្មាភិបាលផ្សេងៗទៀតនៃបក្សកុម្មុយនីស្តកម្ពុជា មានគោលបំណងរួម ក្នុងការអនុវត្តគោលនយោបាយ [ទាំងបួន] របស់ ប.ក.ក។

[...]

[មាស] មុត ក៏បានចូលរួមចំណែកយ៉ាងសំខាន់ផងដែរក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ដោយផ្តោតលើក្រុមជាក់លាក់ ដែលត្រូវបានចាត់ទុកថាជាការគំរាមកំហែងសក្តានុពល ឬមិនស្មោះត្រង់ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសកម្មាភិបាល ប.ក.ក ដែលត្រូវបានចោទប្រកាន់ពី "សកម្មភាពក្បត់" "ប្រជាជន ១៧ មេសា" ទាហានមកពីភូមិភាគបូព៌ា និង ជនជាតិវៀតណាម និងថៃ ជាអាទិ៍ តាមរយៈការប្រកាសក្រុមទាំងនោះថាជាជនក្បត់ និង/ឬជា ខ្មាំង បញ្ជាឱ្យកំណត់អត្តសញ្ញាណ ចាប់ខ្លួន និងសម្លាប់ពួកគេ និងតាមរយៈការគាំទ្រការបោស សម្អាតក្រុមជាក់លាក់ទាំងនេះ *នៅក្នុងតំបន់ដែលគាត់មានអំណាច* និងជាពិសេស នៅពេល ដែលមានការណែនាំឱ្យធ្វើដូច្នេះ *នៅខាងក្រៅតំបន់*នោះ[153]។

71. ដូចបានកត់សម្គាល់ពីខាងដើមរួចមកហើយ មានការយល់ស្របថា ព្យសនកម្មដែលបានរៀបរាប់ដោយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ផ្ទុយទៅវិញ សហមេធាវីតវ៉ាថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ទាំងអស់*ដែលចោទប្រកាន់ថា ខ្លួនទទួលរងព្យសនកម្មដោយសារតែជាសមាជិកនៃក្រុមគោលដៅ ជាក់លាក់ អាចទទួលយកបាន សូម្បីតែនៅពេលព្យសនកម្មនោះពុំបណ្តាលមកពីការកំណត់គោលដៅទៅ លើសមាជិកនៃក្រុមជាក់លាក់ នៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងដែនកោះក្បែរឆ្នេរ សមុទ្រ របស់កម្ពុជាប្រជាធិបតេយ្យ ឬនៅក្នុងអំឡុងពេលបោសសម្អាតកងពល១១៧ កងពល១៦៤ កងពល៣១០ និងកងពល៥០២ ក្តី[154]។ ឧទាហរណ៍ សហមេធាវីពិពណ៌នាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

---

[153] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៦២, ៥៦៨ (គូសបញ្ជាក់បន្ថែម)។ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា "តំបន់ដែលគាត់មានអំណាច" គឺសំដៅទៅតំបន់កំពង់សោម បណ្តាកោះ និងដែនទឹកនៅតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ចំណែកឯ "នៅខាងក្រៅតំបន់នោះ" គឺសំដៅទៅលើការបោសសម្អាតកងពល១១៧ ១៦៤ ៣១០ និង ៥០២។

[154] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៧ ("ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបណ្តាលមកពីការកំណត់គោលដៅ) សុទ្ធតែបានផ្តល់ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

ប្បវេណី ប៉ាង ស្រី ដែលត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅជាមួយនឹងគ្រួសាររបស់គាត់ ដែលបានរៀបរាប់ថាជា "ប្រជាជនថ្មី" ចេញពីភ្នំពេញឆ្ពោះទៅខេត្តកណ្តាល ហើយដែលឪពុករបស់គាត់ជាអតីតទាហាន លន់ នល់ ត្រូវបានគេយកទៅសម្លាប់ចោលនៅមន្ទីរឃុំឃាំងក្រាំងតាចាន់ ស្ថិតនៅក្នុងខេត្តតាកែវ[155]។ ទោះបីជាចៅក្រមអន្តរជាតិយល់ស្របថា ករណីទាំងនេះអាចបង្កឲ្យមានការឈឺចាប់ និងអាចជាប់ពាក់ព័ន្ធនឹងគោលនយោបាយ ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហមក៏ដោយ ក៏ព្យសនកម្មដែលត្រូវបានចោទប្រកាន់នេះ ពុំបណ្តាលមកពីការកំណត់គោលដៅទៅលើអតីតបុគ្គលិកយោធា និង "ប្រជាជនថ្មី" នៅក្នុងតំបន់កំពង់សោម ឬនៅក្នុងដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនទាក់ទិនទៅនឹងការបោសសម្អាតដែលបានបញ្ជាក់ជូនខាងលើនោះទេ ដូច្នេះហើយពុំអាចទម្លាក់កំហុសទៅលើ មាស មុត បានទេ។

72. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនង នៅក្នុងវិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងកំណត់ថា សច្ចធារណ៍នៃព្យសនកម្មជាសម្ភូតភាពនៅក្នុងរឿងក្តីបច្ចុប្បន្ន ពង្រីករហូតដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចភ្ជាប់ព្យសនកម្មរបស់ពួកគេជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងប្រឆាំងនឹងជនរងគ្រោះផ្ទាល់ នៅក្នុងតំបន់កំពង់សោម ដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ និងការបោសសម្អាតកងពលធំដូចបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[156]។ តាមពិត "ត្រឹមជាសមាជិកនៃក្រុមគោលដៅជាក់លាក់នៅកន្លែងផ្សេង ដោយពុំមានទំនាក់ទំនងជាមួយនឹង [ទីកន្លែងទាំងនេះ] គឺពុំគ្រប់គ្រាន់នោះទេ"[157]។ ទោះបីជាចៅក្រមអន្តរជាតិសង្កេតឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនមិនអាចទទួលយកបាន បានបង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហមេធាវី និងអ្នកដែលមានឈ្មោះនៅក្នុង

ព័ត៌មានគ្រប់គ្រាន់ ដើម្បីបង្ហាញពីសមាជិកភាពរបស់ពួកគេនៅក្នុងក្រុម ឬសហគមន៍គោលដៅជាក់លាក់មួយ ឬច្រើន ដូចដែលបានកំណត់អត្តសញ្ញាណនៅក្នុងសារណា។ ដោយផ្អែកលើមូលដ្ឋាននេះ [អង្គបុរេជំនុំជម្រះ] គួរច្រានចោលដីកាស្តីពីភាពអាចទទួលយកបាន ហើយសម្រេចទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងអស់នេះជាដើមបណ្តឹងរដ្ឋប្បវេណី" (គូសបញ្ជាក់បន្ថែម)។

[155] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៦(៦)។

[156] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៦៨។

[157] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៦៨។

ឧបសម្ព័ន្ធ គ នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន[158] អាចទទួលរងព្យសនកម្មផ្លូវចិត្តដោយសារលទ្ធផលដែលពួកគេត្រូវបានចាត់ទុកជាសមាជិកនៃក្រុមគោលដៅជាក់លាក់ក៏ដោយ ក៏ព្យសនកម្មរបស់ពួកគេពុំជាប់ទាក់ទងនឹង "ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" នៅក្នុងរឿងក្តីនេះទេ។ ដូច្នេះហើយ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសអង្គច្បាប់ឡើយ ក្នុងការច្រានចោលអ្នកដាក់ពាក្យសុំទាំងនេះ។ អាស្រ័យហេតុនេះ សម្រេចច្រានចោលមូលដ្ឋានទី១(២)នៃបណ្តឹងឧទ្ធរណ៍។

## ឃ. មូលដ្ឋានទី ១(៣)

73. ពាក់ព័ន្ធនឹងបញ្ហាថា តើព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង តម្រូវឱ្យមានទំនាក់ទំនងទៅនឹងទីតាំងឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មដែលលើកឡើងក្នុងដីកាដំណោះស្រាយ ឬយ៉ាងណានោះ ចៅក្រមអន្តរជាតិសូមរម្លឹកថា វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងកំណត់ថា ព្យសនកម្មត្រូវតែជាផលវិបាកដោយផ្ទាល់ ដែលយ៉ាងហោចណាស់ក៏កើតចេញពីចំណោមឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ហើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងព្យសនកម្ម ដែលពុំកើតចេញពីចំណោមឧក្រិដ្ឋកម្មដែលត្រូវបានកំណត់ទីតាំងនៅក្នុងតំបន់កំពង់សោម ឬនៅក្នុងដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ឬដែលបានជាប់ទាក់ទងនឹងការបោសសម្អាតដូចបានលើកឡើងខាងលើ មិនបំពេញលក្ខខណ្ឌតម្រូវពីទំនាក់ទំនងនៅក្នុងវិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃនោះទេ[159]។ ចៅក្រមអន្តរជាតិសូមលើកឡើងសាជាថ្មីថា៖

> វិធាន ២៣ *ស្ទួន*(១)(ខ) មិនតម្រូវឱ្យមានទំនាក់ទំនងហេតុ និងផល រវាងព្យសនកម្មដែលត្រូវបានស៊ើបអង្កេតនោះឡើយ គឺវាតម្រូវឱ្យមានទំនាក់ទំនងហេតុ និងផល រវាងព្យសនកម្ម និងឧក្រិដ្ឋកម្មណាមួយដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះ។ ឧក្រិដ្ឋកម្ម គឺជាការកំណត់ប្រភេទបទល្មើសដែលត្រូវបានស៊ើបអង្កេត [...]។ វាគឺជាការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេត មិនមែនជាស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេត។ ទោះបីជាអង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុ [...] បានរួមបញ្ចូលនូវ [...] អំពើសាហាវ

---

[158] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៣៦(១)-(៦)។ សូមមើលផងដែរ ឧបសម្ព័ន្ធ គ ភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3.2.3)។

[159] *សូមមើលខាងលើ* កថាខណ្ឌ ៦៣។

> ឃោរឃៅជាទ្រង់ទ្រាយធំ [...]។ វាគឺជាការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេត មិនមែនស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេតនោះទេ ដែលសហចៅក្រមស៊ើបអង្កេតគួរពិចារណាគួរធ្វើការពិចារណា នៅពេលដែលខ្លួនធ្វើការពិនិត្យទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ២៣ ស្ទួន(១)(ខ)[160]។

74. អាស្រ័យហេតុនេះ ព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងនោះ គួរតែជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុន្តែ វាមិនតម្រូវឱ្យជាប់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ណាមួយ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបំពេញលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល នៅក្រោមវិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងនោះទេ។

75. ចៅក្រមអន្តរជាតិសូមរំលឹកឡើងវិញទៀតថា "វត្ថុបំណង និងគោលបំណងនៃវិធាន ២៣ ស្ទួន(១) នៃវិធានផ្ទៃក្នុង មិនមែនបង្កើតឡើងសម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នោះទេ[161]"។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ការបកស្រាយនេះ គឺស្របគ្នាជាមួយនឹងគោលការណ៍ជាសារវ័ន្តនៃនីតិវិធីរបស់ អ.វ.ត.ក ដែលមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដែលមានបំណងធានាការពារដល់ផលប្រយោជន៍របស់ភាគីទាំងអស់ ហេតុដូច្នេះហើយ តម្រូវឱ្យអង្គបុរេជំនុំជម្រះការពារផលប្រយោជន៍របស់ជនជាប់ចោទផង និងផលប្រយោជន៍របស់ជនរងគ្រោះផង។

76. ដូចសហចៅក្រមស៊ើបអង្កេតបានលើកឡើងយ៉ាងត្រឹមត្រូវហើយ នៅក្នុងសំណុំរឿងបច្ចុប្បន្ន ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ដើម្បីបំពេញលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល នៅក្រោមវិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទីមួយ ត្រូវតែបង្ហាញថា ព្យសនកម្មនេះកើតចេញពីការអនុវត្តគោលនយោបាយមួយ ក្នុងចំណោមគោលនយោបាយទាំងបួនរបស់ខ្មែរក្រហម ទោះបីជានៅទីតាំងណាមួយដែលស្ថិតនៅក្នុងតំបន់ដែលបានលើកឡើងខាងលើក្តី ឬនៅក្នុងបរិបទ

---

[160] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់បណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៤២ (គូសបញ្ជាក់បន្ថែម)។

[161] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍របស់បណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៦២។

នៃការបោសសម្អាតកងពល១១៧ កងពល១៦៤ កងពល៣១០ និងកងពល៥០២ ក្តី[162]។ ទីពីរ ការអនុវត្ត គោលនយោបាយទាំងនេះនាំឲ្យកើតអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្ម សង្គ្រាម និង/ឬ ឧក្រិដ្ឋកម្មជាតិ ដែលស្ថិតនៅក្រោមមាត្រា ៣ ថ្មីនៃច្បាប់ អ.វ.ត.ក និងទីបី ឧក្រិដ្ឋកម្មបែប នេះណាមួយ អាចកើតឡើងដោយសារតែ មាស មុត[163]។

77. ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា អនុលោមតាមមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ អ្នកដាក់ ពាក្យសុំដែលអះអាងថាមានព្យសនកម្មកើតចេញពីឧក្រដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែលមិនបានកើត ឡើងនៅទីតាំងឧក្រិដ្ឋកម្មណាមួយជាក់លាក់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុន្តែ វាបានបណ្តាលមកពី ការអនុវត្តគោលនយោបាយទាំងឡាយរបស់ ប.ក.ក នៅក្នុងតំបន់ដែលគាត់មានអំណាច[164] គួរត្រូវបាន ទទួលយក។ ក្នុងន័យនេះ ចៅក្រមអន្តរជាតិសម្គាល់ឃើញថា ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងទាំង ចៅក្រមអន្តរជាតិ នៅក្នុងការពិចារណារបស់ពួកគាត់ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ បានសន្និដ្ឋានថា មាស មុត *ជាអាទិ៍* មានអំណាចគ្រប់គ្រងទៅលើតំបន់កំពង់សោម ដែលយ៉ាងហោចណាស់ ជាទីតាំងមួយគ្របដណ្តប់ទៅលើក្រុងកំពង់សោម ស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងតំបន់ឆ្នេរសមុទ្ររបស់ កម្ពុជាប្រជាធិបតេយ្យ[165] ក្នុងឋានៈគាត់ជាលេខាតំបន់ស្វយ័តកំពង់សោម និងជាមេបញ្ជាការកងពល

---

[162] *សូមមើល* ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D269) កថាខណ្ឌ ៣៦-៣៨។

[163] *សូមមើល* ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D269) កថាខណ្ឌ ៣៦-៣៨។

[164] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ៥៦៤-៥៦៨។

[165] *សូមមើល* ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D269) កថាខណ្ឌ ៣៦-៣៨។ សូម មើលផងដែរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៦០, ៤២៦, ៤៤៦ (ដែលលើកឡើងពីក្រុងកំពង់សោម) កថា ខណ្ឌ ៣៥៥-៤០២ (ដែលពិនិត្យមើលទៅលើឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្តនៅស្រុកស្ទឹងហាវ) និង កថាខណ្ឌ ៤០៣-៤៤៦ (ដែលនិយាយសំដៅទៅលើឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្តនៅស្រុកព្រៃនប់ រួមទាំងអូរឧកញ៉ាហេង)។ ឧបសម្ព័ន្ធ ក ភ្ជាប់ទៅ នឹងដីកាសម្រេចលើភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D269.1) ដែលក្នុងនោះ សហចៅក្រមស៊ើប អង្កេតអន្តរជាតិបានទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលរងព្យសនកម្មពីឧក្រិដ្ឋកម្ម ទាំងឡាយប្រព្រឹតឡើងនៅក្នុងស្រុកព្រៃនប់ ខេត្តកំពង់សោម (សូមមើល ឧទាហរណ៍ កេត ឡុច (13-VSS-00727) ដែល សម្រេចទៅលើ "ការបាត់ខ្លួនឪពុករបស់អ្នកដាក់ពាក្យសុំពីចម្ការចុះរេននៅក្នុងស្រុកព្រៃនប់ ខេត្តកំពង់សោម"។ វង់ ភៀន (11-VSS-00296) ដែលសម្រេចថា លោកស្រីត្រូវបានគេដាក់ឲ្យទៅជាទាសករ និងប្រឈមមុខទៅនឹងស្ថានភាពរស់នៅដោយ អមនុស្សធម៌ "នៅក្នុងស្រុកព្រៃនប់" (គូសបញ្ជាក់បន្ថែម))។

១៦៥[166]។

78. បន្ទាប់ពីបានពិនិត្យទៅលើផ្នែកពាក់ព័ន្ធនៃឧបសម្ព័ន្ធ ខ នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវី ដោយអនុលោមតាមលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល នៅក្នុងវិធាន ២៣ *ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងតំបន់កំពង់សោមនោះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងសេចក្តីសម្រេចរបស់គាត់អំពីភាពអាចទទួលយកបាននអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីនាក់ និងយល់ឃើញថា ដូចបានបង្ហាញហេតុផលក្នុងឧបសម្ព័ន្ធ ១ នៃមតិយោបល់នេះ ជនរងគ្រោះដូចខាងក្រោមនេះ គួរត្រូវបានទទួលស្គាល់៖ អន ដារ៉ាវុធ (17-VSS-00043), អ៊ូច សាគម (14-VSS-00016), គង់ សំណាង (11-VSS-00301)[167]។

79. លើសពីនេះទៀត បន្ទាប់ពីបានពិនិត្យមើលទៅលើឧបសម្ព័ន្ធ គ និង ឃ នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវី ដែលអះអាងថាមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិនតែទៅនឹងមូលដ្ឋានបណ្តឹងឧទ្ធរណ៍ទី១(១) និង១(២) រួចមក ចៅក្រមអន្តរជាតិកត់សម្គាល់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយនាក់ផ្សេងទៀត គឺ វង់ គឹមស្នួន (11-VSS-00293) បំពេញនូវលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងហេតុ និងផលនៃវិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងតំបន់កំពង់សោម។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងការសម្រេចរបស់ខ្លួនស្តីពីភាពអាចទទួលយកបាន ទៅលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ និងយល់ឃើញថា គាត់គួរត្រូវបានទទួលស្គាល់ ដូចបានបញ្ជាក់ជូននៅក្នុងឧបសម្ព័ន្ធ ១ នៃមតិយោបល់នេះ។ អាស្រ័យហេតុនេះ សម្រេចតម្កល់មូលដ្ឋានទី១(៣) នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវី សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនរូបនេះ និងច្រានចោលអ្នកដាក់ពាក្យសុំដែលនៅសេសសល់។

---

[166] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៣១៥-៣២៤, ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267) កថាខណ្ឌ ១៥៩-១៦១។

[167] *សូមមើល* ឧបសម្ព័ន្ធ ១។

01672725



## ខ. មូលដ្ឋានទី ២៖ ការចោទប្រកាន់អំពីកំហុសដែលពាក់ព័ន្ធនឹងផលប៉ះពាល់កើតចេញពីដីកាសម្រេច ស្របតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង

### ១. សារណា

80. នៅក្នុងមូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍របស់ពួកគេ សហមេធាវីបានសន្និដ្ឋានថា ទោះបីជាសេចក្តីថ្លែងការណ៍ដដែលៗរបស់ខ្លួនថា ដីកាសម្រេចស្របតាមវិធាន ៦៦*ស្ទួន* មិនប៉ះពាល់ដល់ភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមតំបន់ស្វយ័តកំពង់សោម និងផ្ទៃទឹក ព្រមទាំងបណ្តាកោះនៃឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ[168]។ សហមេធាវីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានច្រានចោលដោយភាន់ច្រឡំ និងបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ **ខ** នៃបណ្តឹងឧទ្ធរណ៍[169] ដែលបានទទួលរងការខូចខាតដោយសារផលវិបាកនៃឧក្រិដ្ឋកម្ម ដូចបានចោទប្រកាន់នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច ដោយហេតុថា ប្រសិនបើករណីនេះមិនបានកើតឡើងទេនោះ អ្នកដាក់ពាក្យសុំទាំងនេះអាចត្រូវបានទទួលស្គាល់នៅមុនចេញដីកាសម្រេចស្របមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[170]។

81. សហមេធាវីអះអាងថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រឹតត្បិតវិសាលភាពភូមិសាស្ត្រលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាការបដិសេធប្រតិសកម្មចំពោះសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ដែលពីមុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងដំណើរការនីតិវិធី ០០៣[171]។ សហមេធាវីបានបន្ថែមថា ការបកស្រាយរបស់គាត់អំពីផលប៉ះពាល់នៃការកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតរបស់

[168] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤២។

[169] អ្នកដាក់ពាក្យសុំ អួន ហាន (13-VSS-00452), គង់ សៀក (16-VSS-00054), ម៉ាន់ រ៉ៃ (13-VSS-00453), នាង ឡាយ (13-VSS-00499), ង៉ូវ ញ៉ា (13-VSS-00602), អ៊ុម នាង (14-VSS-00129), សុខ ពេជ្រ (13-VSS-00517) និង ស៊ូ យឹម (11-VSS-00130)។

[170] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤១-៤៧។

[171] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៣-៤៥។

តុលាការគឺផ្ទុយទៅនឹងសិទ្ធិរបស់ជនរងគ្រោះ និងគោលការណ៍ជាសារវ័ន្ត នៃ អ.វ.ត.ក ដែលតម្រូវឱ្យតុលាការពិចារណាក្នុងក្របខណ្ឌទូលំទូលាយ អំពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីការពារផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ[172]។

82. ហេតុដូច្នេះ សហមេធាវី ស្នើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយសារបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ **ខ** នៃបណ្តឹងឧទ្ធរណ៍របស់ពួកគេ ដែលទទួលរងនូវការខូចខាតដោយសារផលវិបាកនៃឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងដីកាសម្រេចស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[173]។

## ២. ការពិភាក្សា

83. ចៅក្រមអន្តរជាតិសូមរំលឹកថា អនុលោមតាមវិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង គោលបំណងនៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺដើម្បី "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់" ហើយក៏បានបញ្ជាក់ជាថ្មីថា យោងតាមបុព្វកថានៃកិច្ចព្រមព្រៀង ចៅក្រម និងអង្គជំនុំជម្រះនៃ អ.វ.ត.ក ត្រូវតែយកចិត្តទុកដាក់ខ្ពស់ និងធានានូវការចូលរួមប្រកបដោយអត្ថន័យសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង[174]។ ចៅក្រមអន្តរជាតិសង្កេតឃើញទៀតថា យោងតាមវិធាន ២៣*ស្ទួនពីរ*(២) នៃវិធានផ្ទៃក្នុង "នៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយមេធាវី សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានអនុវត្តតាមរយៈមេធាវីនោះ" ហើយកត់សម្គាល់ថា អនុលោមតាមវិធាន ៧៤(៤)(i) នៃវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការអនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង"។

84. ចំពោះការសន្និដ្ឋានរបស់សហមេធាវី ទាក់ទងនឹងការចោទប្រកាន់លើផលប៉ះពាល់ដែលបង្កឡើង

[172] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៦។

[173] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៧។

[174] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦៥។

ដោយដីកាសម្រេចកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតរបស់តុលាការ អនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ចៅក្រមអន្តរជាតិបានរំលឹកអំពីវិធាន ៦៦*ស្ទួន*(៥) នៃវិធានផ្ទៃក្នុង ដែលចែងថា ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញនៅតែអាចយកមកសំអាងដដែល ដរាបណាវាពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់ ហើយកត់សម្គាល់ថា ដីកាសម្រេចដែលរងការជំទាស់ បានដកចេញអង្គហេតុ និងអង្គច្បាប់ ព្រមទាំងការចោទប្រកាន់ទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច មិនត្រូវបានដាក់ទៅលើ មាស មុត[175] ទេ ហើយកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងនេះត្រូវបានបញ្ចប់ដោយដីកាសម្រេចអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[176]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិពិចារណាឃើញថា សេចក្តីសន្និដ្ឋានរបស់សហមេធាវីក្នុងរឿងនេះ មិនមានលក្ខណៈសមហេតុផល និងបានលើកឡើងយឺតពេលនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេ ដោយសារហេតុផលដូចខាងក្រោម។

85. ចំណុចទី១ ចៅក្រមអន្តរជាតិសង្កេតឃើញថា ដោយគោរពតាមដីកាសម្រេចរបស់សហចៅក្រមអន្តរជាតិស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង សហមេធាវីត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ និងផ្តល់នូវឱកាសសមស្របដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រកបដោយអត្ថន័យ។ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណើសុំយោបល់របស់ខ្លួន បានជូនដំណឹងដល់ភាគីនានាថា ខ្លួនមានបំណងដកអង្គហេតុជាក់លាក់ចេញពីការស៊ើបអង្កេត និងស្នើសុំឱ្យពួកគេផ្តល់យោបល់លើបញ្ហានេះ[177]។ ក្រោយទទួលបានយោបល់ពីសហមេធាវីការពារក្តី មាស មុត និងសហព្រះរាជអាជ្ញាអន្តរជាតិ នៅពេលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងស្តីពីការផ្អាកកិច្ចស៊ើបសួរជាបណ្តោះអាសន្ន នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦[178]។ នៅក្នុងសេចក្តីជូនដំណឹងអនុលោមតាមវិធានផ្ទៃ ៦៦*ស្ទួន* (២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងជាផ្លូវការដល់ភាគីអំពីចេតនារបស់ខ្លួន ក្នុងការដកចេញអង្គហេតុដែលបានចោទប្រកាន់មួយចំនួន

---

[175] សិទ្ធិអំណាចតាមអង្គច្បាប់ និងអង្គហេតុទាំងនេះរបស់ ស៊ូ ម៉េត *សូមមើលសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* (ឯកសារ D1) កថាខណ្ឌ ៤៧, ៦៦, ៧៣-៧៥។

[176] ដីកាសម្រេចអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង (ឯកសារ D226) កថាខណ្ឌ ៤, ១៣។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D267) កថាខណ្ឌ ៥៨០។

[177] សំណើសុំផ្តល់យោបល់ (ឯកសារ D184)។

[178] សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន (ឯកសារ D184/3)។

ហើយបានអញ្ជើញភាគីទាំងអស់ឱ្យដាក់សេចក្តីសន្និដ្ឋានក្នុងរយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង[179]។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង របស់ខ្លួន ដែលក្នុងនោះខ្លួនបានបញ្ជាក់ថា ការដកចេញអង្គហេតុ "នឹងមិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ សិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ"[180]។ ចំណុចចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបានរបស់ខ្លួន បានបញ្ជាក់យ៉ាងច្បាស់ថា "[អង្គហេតុ] ដែលបានដកចេញយោងតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ហើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានចោទនោះ អាចនៅតែជាមូលដ្ឋាននៃដីកាសម្រេចលើភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើបានបំពេញតាមលក្ខខណ្ឌផ្សេងទៀត"[181]។

86. ចៅក្រមអន្តរជាតិកត់សម្គាល់ដោយសោកស្តាយថា សហមេធាវីមិនបានដាក់សារណាណាមួយឆ្លើយតបទៅនឹងសំណើសុំយោបល់ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ឬ សេចក្តីជូនដំណឹងស្របតាមវិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុងនោះឡើយ។ ជាងនេះទៅទៀត សហមេធាវីមិនបានប្រើប្រាស់សិទ្ធិដែលមានចែងជាក់លាក់របស់ខ្លួនស្របតាមវិធាន ៧៤(៤)(i) នៃវិធានផ្ទៃក្នុង ធ្វើការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរអង្កេតរបស់តុលាការ ក្នុងសំណុំរឿង ០០៣ ពុំអាចមានអានុភាពដោយផ្ទាល់ សំអាងលើអង្គហេតុដែលបានដកចេញទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច[182] យកមកបង្កើតជាមូលដ្ឋានសម្រាប់ការចោទប្រកាន់លើលោក មាស មុត ដោយអនុលោមតាមវិធាន ៦៦*ស្ទួន*(៥) នៃវិធានផ្ទៃក្នុងនោះឡើយ។ ចៅក្រមអន្តរជាតិពិចារណាឃើញថា កិច្ចអន្តរាគមន៍ភ្លាមៗរបស់សហមេធាវីដែលបង្ហាញ អំពីផលប៉ះពាល់អវិជ្ជមានដូចខ្លួនបានចោទប្រកាន់ ដោយសារការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការទៅលើសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួម ទំនងអាចនឹងមានប្រយោជន៍ដល់ការធានានូវផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះក្នុងរឿងក្តីនេះ។ យោងតាមសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិយល់ឃើញ

---

[179] សេចក្តីជូនដំណឹងស្របតាមវិធាន ៦៦ស្ទួន(២) នៃវិធានផ្ទៃក្នុង (ឯកសារ D184/4) កថាខណ្ឌ ៨-៩។

[180] ដីកាសម្រេចយោងតាមវិធាន ៦៦*ស្ទួន* (ឯកសារ D226) កថាខណ្ឌ ១២។

[181] ដីកាសម្រេចលើភាពអាចទទួលយកបាន (ឯកសារ D269) កថាខណ្ឌ ៣៩។

[182] ដីកាសម្រេចស្របតាមវិធាន ៦៦*ស្ទួន* (ឯកសារ D226) កថាខណ្ឌ ៤ និង ១៣។

ថា សហមេធាវីខកខានមិនបានអនុវត្តសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងរឿងក្តី ឱ្យបានទាន់ពេលវេលា។

87. ចំពោះការអះអាងរបស់សហមេធាវីអំពីផលប៉ះពាល់ដែលខ្លួនចោទប្រកាន់ថា បានកើតឡើងបណ្តាលមកពីការកាត់បន្ថយវិសាលភាពនៃការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយដីកាសម្រេចស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ចៅក្រមអន្តរជាតិបញ្ជាក់ថា អង្គហេតុនានាដែលបានដកចេញស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ដូចបានយល់ឃើញដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅតែអាចបង្កើតជាមូលដ្ឋាននៃសេចក្តីសម្រេចអំពីភាពអាចទទួលយកបានដដែល ប្រសិនបើបានបំពេញល័ក្ខខ័ណ្ឌដែលនៅសល់នៃភាពអាចទទួលយកបានស្របតាមវិធាន ២៣*ស្ទួន* (១) និង (៤) នៃវិធានផ្ទៃក្នុង[183]។ ត្រង់ករណីនេះ ចៅក្រមអន្តរជាតិសូមរំលឹកថា អនុលោមតាមវិធាន ២៣*ស្ទួន*(៤) នៃវិធានផ្ទៃក្នុង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវតែមាន "ព័ត៌មានគ្រប់គ្រាន់" ដើម្បីអាចឱ្យមានការផ្ទៀងផ្ទាត់អំពីការអនុវត្តស្របតាមវិធានផ្ទៃក្នុង[184]។ នៅពេលបញ្ជាក់ជាថ្មីអំពី "វិធីសាស្ត្រអាចបត់បែនបាន" របស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំទាំងអស់ក្នុងការបង្ហាញអត្តសញ្ញាណរបស់ពួកគេឱ្យបានច្បាស់[185] ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហមេធាវីមិនបានផ្តល់សេចក្តីសេចក្តីផ្លានលើអង្គច្បាប់ ឬ អង្គហេតុនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេ ដើម្បីបង្ហាញថា ពាក្យសុំរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ខ នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន បានបំពេញលក្ខខណ្ឌគតិយុត្តិនៃភាពអាចទទួលយកបានស្របតាមវិធាន ២៣ស្ទួន (១) និង (៤) នៃវិធានផ្ទៃក្នុង នោះឡើយ។ ម្យ៉ាងវិញទៀត សហមេធាវីមិនបានផ្តល់នូវព័ត៌មានគ្រប់គ្រាន់ដែលបង្ហាញអំពីអត្ថិភាពនៃទំនាក់ទំនងហេតុនិងផល រវាងឧក្រិដ្ឋកម្ម *នៅក្នុង* បណ្តឹងដាក់ជូនសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ដែលបានកាត់បន្ថយដោយដីកាស
និងព្យសនកម្មរបស់អ្នកដាក់ពាក្យសុំនោះឡើយ។ ទោះជាយ៉ា

[183] *សូមមើល កថាខណ្ឌ ៣៤-៤១ ខាងលើ* (គោលការណ៍ច្បាប់ស្តីពីភាព
[184] វិធាន ២៣ស្ទួន(៤)។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីកា
ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ("សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស
[185] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ស្តីពីបណ្តឹងឧទ្ធរណ៍របស
៩៤។ សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរ
ដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (

ចិត្តទុកដាក់លើព័ត៌មានដែលផ្តល់ដោយជនរងគ្រោះ ដូចបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ខ នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវី[186] ដើម្បីការពារផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ។

៨៨. ក្រោយពីពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវពាក្យសុំ និងព័ត៌មានដែលបានផ្តល់បន្ថែមរួចមក ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឡើយ ក្នុងការបដិសេធជនរងគ្រោះដូចបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ **ខ** នៃបណ្តឹងឧទ្ធរណ៍[187] ដែលបានទទួលរងពន្យសនកម្ម ដោយសារឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច ដោយហេតុថា អ្នកដាក់ពាក្យសុំទាំងនេះបានទទួលរងព្យសនកម្មពីឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តនៅក្រៅបណ្តឹងដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ដែលត្រូវបានកាត់បន្ថយដោយដីកាសម្រេចស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង។ ហេតុនេះសម្រេចបដិសេធមូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍។

## គ. មូលដ្ឋានទី៣៖ ការចោទប្រកាន់អំពីកំហុសនៃការខកខានមិនបានផ្តល់នូវសេចក្តីសម្រេចមួយ ដោយមានសំអាងហេតុ សម្រាប់ការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

### ១. *សារណា*

89. នៅក្នុងមូលដ្ឋានទី៣ សហមេធាវីបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ដោយមិនបានផ្តល់នូវសេចក្តីសម្រេចដោយមានសំអាងហេតុ សម្រាប់ការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[188]។ សហមេធាវីបានលើកទឡ្ហីករណ៍ថា ដីកាសម្រេចលើភាពអាចទទួលយកបាន មិនបានបំពេញតាមបទដ្ឋានអប្បបរមាដែលបានតម្រូវ ដើម្បីគោរពទៅតាមគោល

---

[186] នៅពេលពិនិត្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមអន្តរជាតិបានពិនិត្យមើលឡើងវិញនូវទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ និងប្រតិចារឹកនៃសក្ខីកម្មក្នុងតុលាការដែលបានផ្តល់ជូនដោយអ្នកដាក់ពាក្យសុំនៅចំពោះមុខ អ.វ.ត.ក។

[187] អ្នកដាក់ពាក្យសុំទាំងនេះគឺ៖ អួន ហាន (13-VSS-00452), គង់ សៀក (16-VSS-00054), ម៉ាន់ រ៉ៃ (13-VSS-00453), នាង ឡាយ (13-VSS-00499), ង៉ូវ ញ៉ា (13-VSS-00602), អ៊ុំម នាង (14-VSS-00129), សុខ ពេជ្រ (13-VSS-00517) និង ស៊ូ យឹម (11-VSS-00130)។

[188] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៨-៥១។

ការណ៍នីត្យានុកូលភាព[189] ដែលយោងតាមគោលការណ៍នេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវ "បង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច"[190]។ ពេលដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានជូនដំណឹងអំពីសំអាងហេតុ ពេលនោះសិទ្ធិប្តឹងឧទ្ធរណ៍ ដែលមានចែងក្នុងវិធានផ្ទៃក្នុង នឹងក្លាយជាគ្មានន័យ[191]។

90. សហមេធាវីបានលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះនាពេលកន្លងមក បានកំណត់ពីបទដ្ឋានអប្បបរមាទាំងនេះ សម្រាប់សេចក្តីសម្រេចដោយមានសំអាងហេតុ ទាក់ទងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធនៅក្នុងសំណុំរឿង[192]។ ពួកគាត់អះអាងថា ដីកាសម្រេចលើភាពអាចទទួលយកបាន បានច្រានចោល "យ៉ាងច្រើនលើសលប់" នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "*ជារួម* ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវលើពាក្យសុំនីមួយៗ"[193] ហើយ ដូចនៅក្នុងសំណុំរឿង ០០២ ដែរ បានប្រើប្រាស់សំអាងហេតុ ឬការខ្វះសំអាងហេតុ "មានកម្រិតត្រឹមតែពាក្យពេចន៍ពីរបីឃ្លាខ្លីៗ ដែលគេអាចយកមកប្រើប្រាស់ឡើងវិញ បានច្រើនដង"[194]។ ដីកាសម្រេចនេះ បានច្រានចោល "ម្ចាស់បណ្តឹងឧទ្ធរណ៍ជិត ៩៩% ដោយផ្អែកលើមូលហេតុធម្មតា" ដូចជា៖ (i) ពិពណ៌នាអំពីអង្គហេតុដែលស្ថិតក្រៅវិសាលភាពនៃសំណុំរឿង (ii) មិនបានបង្ហាញថា វាអាចជាការពិតដែលថា អ្នកដាក់ពាក្យសុំបានបានទទួលរងព្យសនកម្មជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ ឬ (iii) ពិពណ៌នាអំពីអង្គហេតុដែលមិនពាក់ព័ន្ធនឹងបញ្ហាណាមួយដែលអាចអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំ ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី[195]។ សហ

---

[189] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៨ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៧-៣៨។

[190] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៨ ដកស្រង់ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៩។

[191] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៨។

[192] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៤៣-៤៤ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4)។

[193] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៥០។

[194] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៥០។

[195] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៥០ យោងទៅ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2)

មេធាវីអះអាងបន្ថែមទៀតថា ការមិនមានភាពជាក់លាក់នេះ ធ្វើឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចប្រើប្រាស់សិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួន ប្រកបដោយអត្ថន័យឡើយ[196]។

91. ហេតុនេះ សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះ ច្រានចោលដីកាសម្រេចលើភាពអាចទទួលយកបាន ដោយហេតុថា អ្នកដាក់ពាក្យសុំដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ង នៃបណ្តឹងឧទ្ធរណ៍ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ ត្រូវបានបដិសេធ ដោយផ្អែកលើមូលដ្ឋានដែលបានពិពណ៌នាខាងលើ ដោយពុំមានដីកាសម្រេចដែលមានសំអាងហេតុ[197]។

## ២. ការពិភាក្សា

92. ចៅក្រមអន្តរជាតិសូមរំឭកថា "លក្ខខណ្ឌតម្រូវដែលថា សេចក្តីសម្រេចទាំងអស់របស់តុលាការតម្រូវឲ្យផ្តល់សំអាងហេតុ [...] ជាបទដ្ឋានអន្តរជាតិ"[198]។ ទីមួយ ចៅក្រមអន្តរជាតិពិចារណាថា ការតម្រូវឲ្យមានសេចក្តីសម្រេច ដោយមានសំអាងហេតុ គឺដើម្បីភាគីអាចប្រើប្រាស់ដោយប្រសិទ្ធិភាព នូវសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ តាមវិធាន៧៤ នៃវិធានផ្ទៃក្នុង[199]។ នៅក្នុងសេចក្តីសម្រេចកន្លងមករបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា ទោះបីជា "សហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ច "ផ្តល់ការយល់ឃើញទៅលើកត្តាទាំងអស់" ដែលបានពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ខ្លួននោះឡើយ" សំខាន់បំផុតគឺ

---

[196] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៥០។

[197] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៥១ យោងទៅ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសម្រេចថាមិនអាចទទួលស្គាល់បាន ដោយផ្អែកលើមូលដ្ឋានមិនគ្រប់គ្រាន់ ឧបសម្ព័ន្ធ ង ភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3.2.7 ។

[198] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៨៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨ យោងទៅ សំណុំរឿង ០០២ (អបជ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ២១។

[199] សំណុំរឿង ០០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៨៥។ សូមមើល ផងដែរ វិធាន ៧៤ ("មូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍បុរេជំនុំជម្រះ")។ ជាពិសេសវិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុងចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង" ដីការបស់សហចៅក្រមស៊ើបអង្កេត "ដែលប្រកាសថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលយកបាន"។

ភាគីពាក់ព័ន្ធទាំងអស់ ដឹងអំពីមូលហេតុនៃសេចក្ដីសម្រេចនីមួយៗ"[200]។ ការនេះធ្វើឱ្យភាគីអាចធ្វើសេចក្ដីសម្រេចច្បាស់លាស់ ថាតើប្ដឹងឧទ្ធរណ៍ឬយ៉ាងណា និងប្ដឹងទៅលើមូលដ្ឋានអ្វីដែរ[201]។

93. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាពីកម្រិត នៃភាពលម្អិតដែលបានតម្រូវ នៅក្នុងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅពេលទទួលយកឬច្រានចោល ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយអង្គបុរេជំនុំជម្រះបានសម្រេចថា៖

> ជាទូទៅ សេចក្ដីសម្រេចរបស់តុលាការ ត្រូវបង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្ដីសម្រេច។ ចំណុចត្រង់នេះនឹងធានាថា ភាគីនានាដែលមិនទទួលបានជោគជ័យ នៅក្នុងពាក្យសុំរបស់ខ្លួន អាចត្រូវបានធានាថា អង្គហេតុដែលបានដាក់ជូន និងការលើកឡើងរបស់ខ្លួនទាក់ទងទៅនឹងអង្គច្បាប់ ត្រូវបានយកមកពិចារណា

---

[200] សំណុំរឿង ០០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៨៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើ បណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើ បណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨ យោងទៅ សំណុំរឿង ០០២ (អបជ០៣) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចឃុំខ្លួន អៀង សារី បណ្ដោះអាសន្ន ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/73 កថាខណ្ឌ ៦៦។ សំណុំរឿង ០០២ (អបជ៦៧) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីសំណើសុំដាក់បញ្ចូល ឯកសារភស្ដុតាងបន្ថែម ទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D365/2/10 ("សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងសំណើសុំដាក់សម្ភារៈភស្ដុតាង ទៅក្នុងសំណុំរឿង (ឯកសារ D365/2/10)") កថាខណ្ឌ ២៤។ *សូមមើលផងដែរ* សំណុំរឿង ០០២ (អបជ៦២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ សហមេធាវីការពារក្ដី អៀង ធីរិទ្ធ" ចុះថ្ងៃ ទី១៥ ខែមិថុនា ឆ្នាំ២០១០ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3 ("សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី ប្រឆាំងសំណើសុំបំពេញកិច្ចស៊ើបសួរ (ឯកសារ D353/2/3)") កថាខណ្ឌ ២៣។

[201] សំណុំរឿង ០០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/6) កថាខណ្ឌ ៨៤។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើ បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ (អបជ៤៦) សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 និង D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា) ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/5 ("សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់ ក.ស.ច.ស (ឯកសារ D300/1/5)" កថាខណ្ឌ ៤១។

យ៉ាងត្រឹមត្រូវ និងពេញលេញ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ មានសិទ្ធិទទួលបានការពិចារណាទៅលើ ពាក្យសុំជាឯកត្តបុគ្គលរបស់ខ្លួន និងទទួលបាននូវការបង្ហាញថា ចំណុចនេះពិតជាកើតឡើងមែន បើទោះបីជាសេចក្តីសម្រេចនោះ ត្រូវបានចេញនៅក្នុងទម្រង់មួយខ្លី ឬជាតារាងក៏ដោយ"[202]

94. ក្នុងករណីនេះ អង្គបុរេជំនុំជម្រះពិចារណាថា ចាំបាច់ត្រូវមានសំអាងហេតុដែលលម្អិតជាងនេះ ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ ដោយសារតែសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត គឺមានត្រឹមតែឃ្លាខ្លីៗ (៥ទៅ១៥ពាក្យ) ហើយ "ច្រើនបំផុត" គឺត្រឹមពីរប្រយោគ សម្រាប់ការបដិសេធ ហើយមិនមានភាពជាក់លាក់ ចំពោះពាក្យសុំតាំងខ្លួននីមួយៗផង[203]។ អង្គជំនុំជម្រះសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្ត "កំហុសអង្គច្បាប់ដែលលេចធ្លោ" ដោយមិនបានផ្តល់ឱ្យបានគ្រប់គ្រាន់នូវមូលដ្ឋាននៃការច្រានចោលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[204]។

95. ក្នុងករណីបច្ចុប្បន្ន ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងដីកាសម្រេចលើភាពអាចទទួលយកបានរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់ពីគោលការណ៍គតិយុត្តិ និងលក្ខណៈវិនិច្ឆ័យដែលខ្លួនបានអនុវត្តនៅពេលសម្រេចលើភាពអាចទទួលបានបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[205]។ គោលការណ៍ទាំងអស់នេះ រួមមានប្រភេទនៃជនរងគ្រោះ និងព្យសនកម្មទាក់ទងពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ទំនាក់ទំនងហេតុផលតាមការតម្រូវ រវាងព្យសនកម្មដែលបានទទួលរង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ប្រឆាំងជនត្រូវចោទ បទដ្ឋាននៃការបង្ហាញភ័ស្តុតាង និងព័ត៌មានគ្រប់គ្រាន់[206]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់អំពីវិសាល

---

[202] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩។

[203] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៧, ៣៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៧, ៣៩។

[204] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩-៤០។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩-៤០។

[205] ដីកាសម្រេចលើភាពអាចទទួលយកបាន (ឯកសារ D269)។

[206] ដីកាសម្រេចលើភាពអាចទទួលយកបាន (ឯកសារ D269) កថាខណ្ឌ ១៦-៣៥, ៤០-៤៨។

ភាពនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត ដែលពន្យល់ថា "អ្នកដាក់ពាក្យសុំ ដែលទទួលរងព្យសនកម្មនៅក្នុងតំបន់ស្វយ័តកំពង់សោម និងផ្ទៃទឹក ព្រមទាំងបណ្តាកោះនៃឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ នៅចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នឹងត្រូវបានទទួលយក ដោយផ្អែកលើលក្ខខណ្ឌចំនួនពីរ"[207] ។ ឧបសម្ព័ន្ធដែលពាក់ព័ន្ធ បានផ្តល់នូវព័ត៌មានបន្ថែម ទាក់ទងភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ[208]។ ចៅក្រមអន្តរជាតិពិចារណាថា ដីកាសម្រេចលើភាពអាចទទួលយកបាន ត្រូវបកស្រាយរួមគ្នាជាមួយនឹងឧបសម្ព័ន្ធ។

96. ទោះបីជាសហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងច្រើនលើសលប់*ជារួម* ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវ លើពាក្យសុំនីមួយៗ"[209] តែចៅក្រមអន្តរជាតិយល់ឃើញថា ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើភាពអាចទទួលយកបាន[210] តាមពិតទៅបានបង្ហាញច្បាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាជាបុគ្គល ទៅលើពាក្យសុំតាំងខ្លួននីមួយៗ។ ចៅក្រមអន្តរជាតិសម្គាល់ថា តារាងមានបញ្ចូលផងដែរនូវលេខឯកសារពាក់ព័ន្ធ និងសំអាងហេតុគ្រប់គ្រាន់ សម្រាប់ការសម្រេច លើភាពមិនអាចទទួលយកបាន។

97. ផ្ទុយពីការគ្រាន់តែបញ្ជាក់ថា "ទំនាក់ទំនងហេតុនិងផលចាំបាច់ រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ" ឬថា "អ្នកដាក់ពាក្យសុំ

---

[207] ដីកាសម្រេចលើភាពអាចទទួលយកបាន (ឯកសារ D269) កថាខណ្ឌ ៣៦-៣៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់បន្ថែមថា លក្ខខណ្ឌពីរបន្ថែមទៀតដែលអ្នកដាក់ពាក្យសុំត្រូវបំពេញគឺ៖ (១) ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរងបណ្តាលមកពីការអនុវត្ត គោលនយោបាយមួយក្នុងចំណោមគោលនយោបាយខាងក្រោមនេះ នៅទីតាំងណាមួយនៅក្នុងតំបន់ដែលបានបញ្ជាក់ពីមុន ឬនៅក្នុងបរិបទនៃការបោសសំអាតកងពលធំ ១១៧, ១៦៤, ៣១០ និង ៥០២ និង (២) "មានភស្តុតាងបង្ហាញថា ការអនុវត្តគោលនយោបាយទាំងនេះ អាចជាអំពើប្រល័យពូជសាសន៍ ឬជាឧក្រិដ្ឋកម្មមួយ ឬលើសពីមួយ ក្នុងចំណោមឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិដែលមានចែង ក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក" ពោលគឺ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងទៀត ឬការធ្វើទុក្ខបុកម្នេញ ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មតាមច្បាប់ជាតិ)។

[208] ឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.1)។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2)។

[209] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (ឯកសារ D269/3) កថាខណ្ឌ ៥០។

[210] ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2)។

តាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ នៅក្នុងពាក្យសុំរបស់ខ្លួន ដើម្បីបញ្ជាក់អំពីភាពស្របគ្នា ទៅនឹងវិធាន ២៣ស្ទួន(១) និង(៤) នោះទេ" ដូចដែលបានធ្វើនៅក្នុងសំណុំរឿង ០០២[211] នៅក្នុងឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើភាពអាចទទួលយកបាន នៅត្រង់ជួរ "សំអាងហេតុមិនទទួលយកពាក្យសុំ"[212] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញពីមូលដ្ឋាននៃការសន្និដ្ឋានរបស់គាត់។ ជាក់លាក់ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្លែងបញ្ជាក់ពីព័ត៌មានជាក់លាក់ដែលខ្លួនបានពិចារណាជាដំបូង និងផ្តល់នូវសេចក្តីសន្និដ្ឋានរបស់ខ្លួនថា "អង្គហេតុដែលបានរៀបរាប់ ស្ថិតនៅក្រៅវិសាលភាពសំណុំរឿង" ឬថា "ទំនងជាការពិតជាជាងការមិនពិតដែលថា គាត់បានទទួលរងការឈឺចាប់ ដោយសារតែឧក្រិដ្ឋកម្មមួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទ" ដោយផ្អែកលើការពិនិត្យរបស់ខ្លួនទៅលើអង្គហេតុនានាដែលបានរៀបរាប់ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនម្នាក់ៗ ដែលរួមបញ្ចូលទាំងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ ព្រមទាំងទីតាំង និងពេលវេលា នៅក្នុងពាក្យសុំតាំងខ្លួនរបស់ពួកគាត់[213]។

---

[211] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៧។

[212] ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2)។

[213] សូមមើល ឧទា. ក្នុងចំណោមប្រការផ្សេងទៀត ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2) ទំព័រ ៨ [អ៊ំ គឹមលន់] (សេចក្តីពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះពាក្យសុំរបស់ អ៊ំ គឹមលន់៖ "ការសម្លាប់ពូ/អ៊ំប្រុសរបស់អ្នកដាក់ពាក្យសុំនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៦។ ការបាត់ខ្លួនប្អូនស្រីគាត់ពីខេត្តក្រចេះ ក្នុងឆ្នាំ១៩៧៧។ ការធ្វើឱ្យក្លាយជាទាសករ និងស្ថានភាពរស់នៅបែបអនុស្សធម៌របស់អ្នកដាក់ពាក្យសុំនៅក្នុងខេត្តក្រចេះ" និងសេចក្តីសន្និដ្ឋានរបស់គាត់ថា ទោះបីជា "មានការទទួលស្គាល់ថា ទាំងនេះជាព្រឹត្តិការណ៍ដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តក៏ដោយ តែព្រឹត្តិការណ៍ទាំងនេះមិនពាក់ព័ន្ធនឹងបញ្ហាណាមួយដែលអាចអនុញ្ញាតឱ្យមានការទទួលយកអ្នកដាក់ពាក្យសុំឱ្យចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ដោយសារមិនស្ថិតនៅក្នុងវិសាលភាពនៃរឿងក្តី")។ សូមមើល ផងដែរ ឧទា. ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2) ទំព័រ ៨ [ឌុក ញ៉ៅ] (សេចក្តីពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះពាក្យសុំរបស់ ឌុក ញ៉ៅ៖ "ការសម្លាប់គ្រួសារពូ/អ៊ំប្រុសគាត់ និងបងប្អូនជីដូនមួយពីរនាក់របស់គាត់ និងការធ្វើឱ្យក្លាយជាទាសករចំពោះគាត់នៅស្រុកដំបែរ ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៧ ក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៨ និងខេត្តក្រចេះ" និងសេចក្តីសន្និដ្ឋានរបស់គាត់ថា "ទោះបីវាធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តក៏ដោយ ក៏វាមិនអាចបង្ហាញឱ្យជឿជាក់បានថាជាការពិតដែលថា គាត់បានទទួលរងការឈឺចាប់ ដោយសារផលវិបាកនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះទេ")។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន (D269.2) ទំព័រ ២២ [ជា ប្រេន] (ការពិនិត្យមើលរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះពាក្យសុំរបស់ ជា ប្រេន៖ "ត្រូវបានបង្ខំឱ្យធ្វើការធ្ងន់ធ្ងរនៅតាមទីកន្លែងជាច្រើន [នៅក្នុងខេត្តពោធិសាត់] ខ្វះការថែទាំ

98. ជាសន្និដ្ឋាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់នូវការពន្យល់គ្រប់គ្រាន់ ដោយមានការយោងជាក់លាក់ទៅរកព័ត៌មានលម្អិតនៃពាក្យសុំតាំងខ្លួនដែលពាក់ព័ន្ធ នៅក្នុងការបដិសេធអ្នកដាក់ពាក្យសុំដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ង នៃបណ្តឹងឧទ្ធរណ៍។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា នៅពេលអានរួមគ្នាជាមួយដីកាសម្រេចលើភាពអាចទទួលយកបាន និងឧបសម្ព័ន្ធ ខ នៃដីកាសម្រេចនេះ បានបង្ហាញយ៉ាងគ្រប់គ្រាន់ពីសម្ភារៈដែលត្រូវបានយកមកធ្វើការពិចារណា ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅពេលធ្វើការសម្រេច ហើយដូច្នេះវាបង្ហាញថា ពាក្យសុំតាំងខ្លួននីមួយៗ "ត្រូវបានយកមកពិចារណាយ៉ាងត្រឹមត្រូវ និងពេញលេញ"[214]។ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាសម្រេចលើភាពអាចទទួលយកបាន និងឧបសម្ព័ន្ធ ខ ដែលពាក់ព័ន្ធ គឺមានសំអាងហេតុគ្រប់គ្រាន់ ដែលអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួននីមួយៗ អាចដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងការបដិសេធពាក្យសុំតាំងខ្លួនរបស់គាត់បាន។ ហេតុដូច្នេះ មូលដ្ឋានទី៣ ត្រូវបានបដិសេធចោល។

## ឃ. មូលដ្ឋានទី៤៖ ការចោទប្រកាន់អំពីកំហុសដោយការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារការខកខានពុំបានផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់

### ១. សារណា

99. នៅក្នុងមូលដ្ឋានទី ៤ នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ ដោយបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ច នៃបណ្តឹងឧទ្ធរណ៍របស់

---

សុខភាព ស្ថានភាពរស់នៅបែបអមនុស្សធម៌ដែលគាត់បានជួបប្រទះនៅក្នុងស្រុកបាកាន ខេត្តពោធិសាត់ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ, ការដាក់ក្នុងមន្ទីរឃុំឃាំងចំពោះសមាជិកគ្រួសារគាត់នៅគុកត្រាចក្រោល ស្រុកបាកាន ក្នុងឆ្នាំ១៩៧៨ (អង្គហេតុទាំងនេះត្រូវបានបញ្ជាក់បំភ្លឺក្នុងអំឡុងការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំក្នុងសំណុំរឿង ០០៤") និងសេចក្តីសន្និដ្ឋានរបស់គាត់ថា "ទោះបីជាមានការទទួលស្គាល់ថា ទាំងនេះជាព្រឹត្តិការណ៍ដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តក៏ដោយ តែអង្គហេតុទាំងនេះមិនពាក់ព័ន្ធនឹងបញ្ហាណាមួយដែលអាចអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ")។

[214] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩។

ពួកគេ[215] ដោយការសំអាងថា (១) អ្នកដាក់ពាក្យសុំស្ថិតនៅ "ក្រៅវិសាលភាពនៃពេលវេលានៃសំណុំរឿង (មូលដ្ឋានទី ៥) (២) ពាក្យសុំមិនមានរយៈពេល ឬទីតាំងគ្រប់គ្រាន់ (មូលដ្ឋានទី ៦) ឬ (៣) សក្ខីកម្មមិនស្របគ្នាជាមួយភស្តុតាង ឬមិនស៊ីសង្វាក់គ្នា (មូលដ្ឋានទី ៧) ដែលជាបទដ្ឋានស្តីពីការបង្ហាញភស្តុតាងដែលបានកំណត់ និងភាពគ្រប់គ្រាន់នៃព័ត៌មានដែលត្រូវបានផ្តល់ ដោយអ្នកដាក់ពាក្យសុំទាំងអស់នេះ[216]។

100. ទីមួយ សហមេធាវីតវ៉ាថា ទាក់ទងនឹងវិធាន ២៣ *ស្ទួន*(១) និង (៤) នៃវិធានផ្ទៃក្នុង ក៏ដូចជាមាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ[217] និងព័ត៌មានដែលបានផ្តល់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ត្រូវបានចាត់ទុកថាគ្រប់គ្រាន់ នៅពេលដែលព័ត៌មាននោះអនុញ្ញាតឱ្យ [សហចៅក្រមស៊ើបអង្កេត]ជឿជាក់បានថា អង្គហេតុដែលបានអះអាងអាចជាការពិត"[218]។ សហមេធាវីតវ៉ាបន្ថែមថា ដូចដែលបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ កម្មវត្ថុ និងគោលបំណងនៃវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង គឺដើម្បីកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនមែនដាក់កំហិត ឬកម្រិតលើទស្សនៈនៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នោះឡើយ[219] ហើយការកំណត់របស់វិធាននេះ នៅក្នុងអនុផ្នែកស្តីពីបទប្បញ្ញត្តិទូទៅនៃផ្នែកស្តីពីនីតិវិធីនៃវិធានផ្ទៃក្នុងបញ្ជាក់ថា ការកំណត់នេះត្រូវបកស្រាយជាមួយនឹងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលលើកឡើងពីគោលការណ៍ជាសារវន្តក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ និងធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព[220]។

---

[215] *សូមមើល* ទឡ្ហីករណ៍ស្តីពីភាពអាចទទួលយកបានចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានរកឃើញថាមិនអាចទទួលយកបានទេ ដោយសារតែពុំមានភស្តុតាង ឬពុំមានមូលដ្ឋានពាក់ព័ន្ធគ្រប់គ្រាន់ ឧបសម្ព័ន្ធ ច ភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3.2.9។

[216] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥២-៥៩។

[217] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥២-៥៣ យោងទៅ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២។

[218] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី(D269/3) កថាខណ្ឌ ៥៣ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៩៥។

[219] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៤ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦២។

[220] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៤ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦១។

01672739



101. ពាក់ព័ន្ធនឹងការបង្ហាញភ័ស្តុតាងដែលតម្រូវឱ្យមាន ចំពោះការខូចខាតរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីអះអាងថា "[សហចៅក្រមស៊ើបអង្កេត] ត្រូវតែសម្រេចថាតើមានមូលដ្ឋានអាចឱ្យជឿជាក់បាន *ជាបឋម* ដែលចង្អុលបង្ហាញថា អ្នកដាក់ពាក្យសុំបានទទួលរងព្យសនកម្មដែលទាក់ទងជាមួយអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋាននៃធាតុផ្សំនៅក្នុងសំណុំរឿងដែរឬទេ[221]។

102. ពាក់ព័ន្ធទៅនឹងកត្តាទាំងឡាយ ដែលសម្រាលដល់ការបង្ហាញអំពីព្យសនកម្មតម្រូវឱ្យមានមកលើដើមបណ្តឹងរដ្ឋប្បវេណីនោះ ទីមួយ សហមេធាវីកត់សម្គាល់ឃើញថា ការសម្រេចរបស់អង្គបុរេជំនុំជម្រះថា ដោយសារតែភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានដោះស្រាយនៅ អ.វ.ត.ក "វាជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាតដែលបង្កដោយអំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល ព្រោះការខូចខាតនេះគ្របដណ្តប់ទៅលើផ្នែកជាបុគ្គលនានា ហើយ "ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល ត្រូវតែបានពិនិត្យមើលក្នុងស្ថានភាពពិសេសនៃជម្លោះ" ដោយការទទួលស្គាល់ថា អំពើសាហាវយង់ឃ្នងទ្រង់ទ្រាយធំកើតចេញពីគោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ដែលសំដៅទៅលើបុគ្គល ឬក្រុមជាក់លាក់ ព្រមទាំងសហគមន៍ទាំងមូល[222]។

103. បន្ថែមទៅលើកត្តាចំនួនបីដែលត្រូវបានទទួលស្គាល់ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងដីការបស់គាត់សម្រេចលើភាពអាចទទួលស្គាល់នោះ[223] សហមេធាវីសូមបញ្ជាក់ថា ការរំលោភបំពានរបស់សហចៅក្រមស៊ើបអង្កេតទៅលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង គឺជាកត្តាសម្រាលបន្ថែមមួយទៀតដែលគួរតែត្រូវបានពិចារណា នៅពេលសម្រេចអំពីភាពគ្រប់គ្រាន់នៃភ័ស្តុតាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[224]។ ដើម្បីជាការគាំទ្រ សហមេធាវីតវ៉ាថា សហចៅក្រមស៊ើបអង្កេតខកខានពុំបានជូនដំណឹងដល់ជនរងគ្រោះ ដែលពុំមានសិទ្ធិចូលមើលសំណុំរឿងបាន ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា នៅទូទាំងកិច្ចដំណើរការនីតិវិធីនោះទេ ហើយហេតុដូច្នេះក៏សំអាងទាំងស្រុងទៅលើព័ត៌មានដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត ដោយសារតែចៅក្រមទាំងនោះពុំបានបង្ហាញទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនានាមកដល់ជន

---

[221] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៥។

[222] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៥ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧០។

[223] *សូមមើល* ដីកាសម្រេចលើភាពអាចទទួលយកបាន (D269) កថាខណ្ឌ ៤១។

[224] បណ្តឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៧។

01672740



រងគ្រោះ រហូតដល់រយៈពេលពីរឆ្នាំកន្លះក្រោយមក បន្ទាប់ពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហេតុដូច្នេះ វាបានរាំងដល់លទ្ធភាពរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការធ្វើការស៊ើបអង្កេតឱ្យបានទាន់ពេលវេលា និងវិភាគឱ្យបានត្រឹមត្រូវទៅលើភស្តុតាងពាក់ព័ន្ធ និងផ្ដល់ព័ត៌មានលម្អិតអំពីព្យសនកម្មដែលពាក់ព័ន្ធ[225]។

104. យោងតាមការលើកឡើងខាងលើ សហមេធាវីស្នើឱ្យអង្គបុរេជំនុំជម្រះច្រានចោលការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភាពមិនអាចទទួលស្គាល់ជាជនរងគ្រោះ ដែលបានបដិសេធនៅក្រោមមូលដ្ឋាន នានាពាក់ព័ន្ធទៅនឹងភាពគ្រប់គ្រាន់ និងគុណភាពនៃព័ត៌មាន ហើយហេតុដូច្នេះ ស្នើឱ្យផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីជូនជនរងគ្រោះទាំងអស់នេះ[226]។

## ២. ការពិភាក្សា

105. ចៅក្រមអន្តរជាតិសូមរម្លឹកថា អនុលោមតាមវិធាន ២៣ *ស្ទួន*(៤) នៃវិធានផ្ទៃក្នុង គ្រប់ពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្ដឹងជាមួយនឹងវិធានផ្ទៃក្នុងនេះ[227]។ ជាពិសេស "ពាក្យបណ្ដឹងត្រូវផ្ដល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់"[228]។ ដោយពិចារណាឃើញថា គោលដៅ និងគោលបំណងនៃវិធានទាំងអស់នេះមិនមែន "សម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក" ទេ ប៉ុន្តែគ្រាន់តែដើម្បីកំណត់លក្ខណៈវិនិច្ឆ័យជាមូលដ្ឋានសម្រាប់ភាពអាចទទួលយកបាននោះ[229] អង្គបុរេ

---

225 បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៧។

226 បណ្ដឹងឧទ្ធរណ៍របស់សហមេធាវី (D269/3) កថាខណ្ឌ ៥៨-៥៩។

227 វិធាន ២៣ *ស្ទួន*(៤) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សេចក្ដីណែនាំអនុវត្តស្ដីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២ មាត្រា ៣.៥ និងមាត្រា ៣.៦។

228 វិធាន ២៣ *ស្ទួន*(៤) នៃវិធានផ្ទៃក្នុង។

229 សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៩៤។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦២។

ជំនុំជម្រះបានអនុម័តតាម "វិធីសាស្ត្របែបបត់បែន" ទាក់ទងនឹងលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបង្ហាញភ័ស្តុតាងជាក់លាក់អំពីអត្តសញ្ញាណរបស់ពួកគេ"[230]។

106. ដោយអនុលោមតាមវិធាន ២៣ *ស្ទួន*(១) នៃវិធានផ្ទៃក្នុង នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នោះសហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ"[231]។ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា នៅក្នុងដីកាសម្រេចអំពីភាពអាចទទួលយកបានរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានសម្រេចថា កត្តាកាលៈទេសៈខ្លះ បានសម្រាលដល់កម្រិតនៃបន្ទុកបង្ហាញភ័ស្តុតាងចំពោះព្យសនកម្មតាមការតម្រូវ ដូចជា៖ (ក) ពេលវេលាកន្លងផុតទៅយូរ (ខ) សមត្ថភាពក្នុងការបង្ហាញការឆ្លើយតប ឬការធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវអំពីផលប៉ះពាល់មកលើសុខភាពផ្លូវចិត្ត និង (គ) សមត្ថភាពក្នុងការផ្ដល់ភ័ស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិ និងប្រាក់ចំណូល ដោយសារតែការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ[232]។ ចៅក្រមអន្តរជាតិយល់ឃើញថា វិធីសាស្ត្របែបបទបែននេះចំពោះភ័ស្តុតាងជាឯកសារ និងការបង្ហាញភ័ស្តុតាងអំពីអត្តសញ្ញាណ គឺជាការសមស្រប ដោយពិចារណាមូលដ្ឋានសង្គម និងវប្បធម៌ជាក់លាក់ពិសេសរបស់ប្រទេសកម្ពុជា និងកម្រិតជាក់ស្ដែងនៃភ័ស្តុតាងដែលអាចរកបាន ដែលបណ្ដាលមកពីអំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះ[233]។

---

[230] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៩៥។

[231] វិធាន ២៣ *ស្ទួន*(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៩៥។

[232] ដីកាសម្រេចលើភាពអាចទទួលយកបាន (D269) កថាខណ្ឌ ៥១។

[233] *សូមមើល* សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/6) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៣, ៩៥។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៨៣, ៩៥។

107. ក្រោយពីការពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវី និងពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ទៅលើព័ត៌មានដែលបានផ្ដល់ដោយជនរងគ្រោះ[234] ដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ ច នៃបណ្ដឹងឧទ្ធរណ៍របស់ពួកគេរួចមក[235] ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

[234] នៅក្នុងការពិនិត្យលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមអន្តរជាតិបានពិនិត្យឡើងវិញទៅលើទម្រង់បែបបទនៃពាក្យសុំតាំងខ្លួនជាជនរងគ្រោះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ហើយប្រសិនបើមានដូចជា ព័ត៌មានបន្ថែម របាយការណ៍សង្ខេប កំណត់ហេតុនៃការស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ ព្រមទាំងប្រតិចារឹកនៃសវនាការនៅក្នុងតុលាការ ដែលអ្នកដាក់ពាក្យសុំបានឆ្លើយបំភ្លឺនៅចំពោះមុខ អ.វ.ត.ក។

[235] ឧទាហរណ៍ ទាក់ទងនឹងពាក្យសុំរបស់ យ៉ាន់ សាន (11-VSS-00178) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា "អ្នកដាក់ពាក្យសុំបានរៀបរាប់ពីការធ្វើឱ្យជាទាសករ អាពាហ៍ពិពាហ៍ដោយបង្ខំ និងស្ថានភាពរស់នៅយ៉ាងអមនុស្សធម៌នៅខេត្តមណ្ឌលគីរី។ ទោះបីមានការទទួលស្គាល់ថា ទាំងនេះជាព្រឹត្តិការណ៍ដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តក៏ដោយ តែព្រឹត្តិការណ៍ទាំងនេះ មិនពាក់ព័ន្ធនឹងសាច់រឿងអង្គសេចក្ដីនានា ដែលនឹងត្រូវបានទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្ដឹងរដ្ឋប្បវេណីទេ ដោយសារមិនស្ថិតនៅក្នុងវិសាលភាពនៃរឿងក្ដី។ ការបាត់ខ្លួនប្ដី និងកូនប្រុសគាត់នៅឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ មិនស្ថិតនៅក្នុងវិសាលភាពនៃរឿងក្ដីទេ" ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន (D269.2) ទំព័រ ៦។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការច្រានចោលពាក្យសុំ ដោយសារអង្គហេតុស្ថិតនៅក្រៅវិសាលភាពភូមិសាស្ត្រ និងវិសាលភាពពេលវេលានៃរឿងក្ដីនោះទេ។ ទាក់ទងទៅនឹង ជា ម៉ារី (17-VSS-00001) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរកឃើញថា "អ្នកដាក់ពាក្យសុំបានរៀបរាប់ដូចតទៅ៖ ការធ្វើឱ្យក្លាយជាទាសករចំពោះអ្នកដាក់ពាក្យសុំនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ (ថិរវេលាមិនជាក់លាក់) ការសម្លាប់សាច់ញាតិមីង/អ៊ំស្រី អ្នកដាក់ពាក្យសុំ (ពេលវេលា និងទីកន្លែងមិនជាក់លាក់) និងការបាត់ខ្លួនសមាជិកគ្រួសារពីរនាក់ផ្សេងទៀត (ពេលវេលា និងទីកន្លែងមិនជាក់លាក់)។ អ្នកដាក់ពាក្យសុំ បានផ្ដល់ព័ត៌មានលម្អិតអំពីព្យសនកម្ម ទទួលរងនៅក្នុងខេត្តកំពង់ធំ ដែលស្ថិតនៅក្រៅភូមិសាស្ត្រ និងទំហំសម្ភារនៃរឿងក្ដីនេះ ប៉ុន្តែមិនបានផ្ដល់ព័ត៌មាន ទាក់ទងនឹងព្យសនកម្មទទួលរងដោយសាច់ញាតិដែលអាចឱ្យព្រឹត្តិការណ៍ទាំងនេះស្ថិតនៅក្នុងវិសាលភាពខាងភូមិសាស្ត្រ ឬ ពេលវេលានៃរឿងក្ដី។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសក្នុងការសន្និដ្ឋានថា "ទោះបីវាជាការប៉ះទង្គិចផ្លូវចិត្តក៏ដោយ ក៏អ្នកដាក់ពាក្យសុំមិនបញ្ជាក់ថា វាទំនងជា ការពិតដែលថា គាត់បានទទួលរងនូវផលវិបាកនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដូចបានចោទប្រកាន់" ឧបសម្ព័ន្ធ ខ នៃដីកាស្ដីពីភាពអាចទទួលយកបាន (D269.2) ទំព័រ ១៨។ ទាក់ទងនឹង សឿង ឃៀង (11-VSS-00214) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាលើពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ដែលបានរៀបរាប់ថា៖ "ការធ្វើឱ្យទៅជាទាសករ និងស្ថានភាពរស់នៅដោយអមនុស្សធម៌របស់អ្នកដាក់ពាក្យសុំ និងគ្រួសារអ្នកដាក់ពាក្យសុំ [ក្នុង] [...] ខេត្តពោធិ៍សាត់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ការសម្លាប់កូនៗអ្នកដាក់ពាក្យសុំក្នុងឆ្នាំ ១៩៧៨ ការស្លាប់ឪពុកម្ដាយក្មេកអ្នកដាក់ពាក្យសុំដោយសារការអត់ឃ្លាននៅខែកក្កដា ឆ្នាំ១៩៧៨ ការសម្លាប់ប្រពន្ធអ្នកដាក់ពាក្យសុំ និងកូនៗអ្នកដាក់ពាក្យសុំចាប់ពីឆ្នាំ ១៩៧៨ ដល់ ឆ្នាំ១៩៧៩ ការធ្វើទុក្ខបុកម្នេញខ្មែរក្រោម" និងបានកត់សម្គាល់អំពីភាពមិនស៊ីចង្វាក់គ្នារវាងទម្រង់បែបបទព័ត៌មានជនរងគ្រោះ និងទម្រង់បែបបទព័ត៌មានបន្ថែម។ ទោះបីជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នាក៏ដោយ ការពិនិត្យឡើងវិញដោយចៅក្រមអន្តរជាតិលើឯកសារពាក់ព័ន្ធបង្ហាញថា ភាពមិនស៊ីចង្វាក់គ្នានៃសម្ភារមានទាក់ទង

ពិតជាពុំមានកំហុសនៅក្នុងការវាយតម្លៃរបស់គាត់ ថាតើវា "អាចជាការពិត" ដែរឬយ៉ាងណា ដែលថា អ្នកដាក់ពាក្យសុំបានទទួលរងព្យសនកម្មពីឧក្រិដ្ឋកម្មនានាដែលមាននៅក្នុងបណ្តឹង ដាក់ជូនសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៣ នោះ។ ហេតុដូច្នេះ មូលដ្ឋានទី ៤ នៃបណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

---

ទៅនឹងការស្លាប់កូនអ្នកដាក់ពាក្យសុំ មិនថាពួកគេត្រូវបានសម្លាប់នៅវត្តតាសុខ ឬ ព្រៃនាមខាងក្រោម ក្នុងឆ្នាំ១៩៧៨ (ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ) ឬ បានស្លាប់ដោយការអត់អាហារនៅសហករណ៍ផ្សារអណ្តែតក្នុងឆ្នាំ ដែល "[គាត់] មិនចាំ" (ទម្រង់បែបបទព័ត៌មានបន្ថែម) និងព្យសហកម្មដែលបានរៀបរាប់ថាបានកើតឡើងនៅក្នុងខេត្តពោធិ៍សាត់។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការសន្និដ្ឋានថា "ទោះបីមានការទទួលស្គាល់ថា ព្រឹត្តិការណ៍ទាំងនេះមានការប៉ះទង្គិចផ្លូវចិត្ត ក៏ដោយ វាមិនពាក់ព័ន្ធនឹងបញ្ហាណាមួយ ដែលអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារវាស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តី" ឧបសម្ព័ន្ធ ខ នៃដីកាបង្គាប់ស្តីពីអាច ទទួលយកបាន (D269.2) ទំព័រ ២២។ ចំពោះ ព្រំ សាន (11-VSS-00264) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីការបាត់ខ្លួនសមាជិកគ្រួសារនៅខេត្តសៀមរាប" និង "ការដាក់ឱ្យទៅជាទាសករនៅខេត្តតាកែវ" ជាមួយនឹងភាពមិនស៊ីសង្វាក់គ្នារវាង ទម្រង់បែបបទព័ត៌មានជនរងគ្រោះ (អង្គហេតុកើតឡើងពីឆ្នាំ១៩៧៥) និងទម្រង់បែបបទព័ត៌មានបន្ថែម (អង្គហេតុកើតឡើងពីឆ្នាំ១៩៧៦ បន្ទាប់ពីការនិរទេសចេញពីប្រទេសវៀតណាម)។ ដើម្បីគាំទ្រដល់អំណះអំណាងរបស់ខ្លួនថា មិនមានភាពស៊ីសង្វាក់គ្នាខាងសម្ភារ សហមេធាវីបានគូសបញ្ជាក់ថា អ្នកដាក់ពាក្យសុំរស់នៅក្នុងខេត្តតាកែវនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងត្រូវបានបញ្ជាឱ្យទៅរស់នៅមន្ទីរ ២១ នាពេលមួយដែលមិនបានបញ្ជាក់ជាក់លាក់ មុនឆ្នាំ ១៩៧៧ (ទម្រង់បែបបទព័ត៌មានជនរងគ្រោះ) ហើយអ្នកដាក់ពាក្យសុំត្រូវបានគេដាក់ឱ្យទៅជាទាសករ ហើយត្រូវបង្ខំឱ្យធ្វើការនៅសហករណ៍ឃុំគូសខេត្តតាកែវ ក្នុងពេលវេលា មិនបានបញ្ជាក់ (ទម្រង់បែបបទព័ត៌មានបន្ថែម)។ ទោះជាយ៉ាងនេះក្តី ដោយសារព្យសនកម្មដូចបានពិពណ៌នាបានកើតឡើងនៅក្នុងខេត្តសៀមរាប និងខេត្តតាកែវ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការសន្និដ្ឋានថា "អ្នកដាក់ពាក្យសុំមិនបានបញ្ជាក់ថា វាទំនងជាមិនមែនជាការពិតដែលថា គាត់ទទួលរងនូវផលវិបាកនៃ ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដូចបានចោទប្រកាន់" ឧបសម្ព័ន្ធ ខ នៃដីកាបង្គាប់ស្តីពីភាពអាចទទួលយកបាន (D269.2) ទំព័រ ២២។ ទាក់ទងនឹង ឡុងឈឿម (11-VSS-00308) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាថា អ្នកដាក់ពាក្យសុំបានរៀបរាប់ថា៖ "ការងារដោយបង្ខំ នៅតាមទីកន្លែងជាច្រើនក្នុងខេត្តបាត់ដំបងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់ឪពុកគាត់នៅខេត្តបាត់ដំបង ក្នុងខែកក្កដា ឆ្នាំ១៩៧៧" និងបានកត់សម្គាល់ថា "[ទោះបី] ទម្រង់បែបបទស្តីពីព័ត៌មានបន្ថែម [...] លើកឡើងថាអាពាហ៍ពិពាហ៍របស់គាត់ត្រូវបានបង្ខំក៏ដោយ ក៏អ្នកដាក់ពាក្យសុំពីដំបូងនៅស្ងៀមមិនបានបញ្ជាក់ថា វាជាការបង្ខំ ឬ អត់ ហើយការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំនៅក្នុងសំណុំរឿង ០០៤ បានបង្ហាញថា ការរៀបការនោះមានការព្រមព្រៀង"។ ដោយសារព្យសនកម្មដូចបានរៀបរាប់បានកើតឡើងនៅក្នុងខេត្តបាត់ដំបង សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការសន្និដ្ឋានថា "ទោះបីមានការទទួលស្គាល់ថា ព្រឹត្តិការណ៍ទាំងនេះមានការប៉ះទង្គិចផ្លូវចិត្ត ក៏ដោយ អង្គហេតុដែលបានផ្តល់ជូនដោយអ្នកដាក់ពាក្យសុំ ពុំជាប់ទាក់ទងនឹងបញ្ហាណាមួយ ដែលអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ" ឧបសម្ព័ន្ធ ខ នៃដីកាបង្គាប់ស្តីពីអាចទទួលយកបាន (D269.2) ទំព័រ ២១។

## ង. សេចក្តីសន្និដ្ឋាន

108. ចៅក្រមអន្តរជាតិយល់ឃើញថា ជាការចាំបាច់ក្នុងការបញ្ជាក់បំភ្លឺអំពីផលប៉ះពាល់នៃដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា លើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មុនពេលធ្វើការពិនិត្យមើលលើការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ។

109. សហចៅក្រមស៊ើបអង្កេតជាតិ នៅក្នុងដីកាសម្រេចរបស់គាត់ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[236] បានអះអាងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបួននាក់ ត្រូវបានច្រានចោល[237]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតជាតិ បានសន្និដ្ឋានថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ក្រោយថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ ត្រូវបដិសេធចោល ដោយអះអាងថា ដោយសារតែការស៊ើបអង្កេតតាមផ្លូវតុលាការ ក្នុងសំណុំរឿង០០៣ ត្រូវបានបិទបញ្ចប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[238] ពាក្យសុំតាំងខ្លួនទាំងអស់នេះ ត្រូវបានដាក់ក្រោយកាលបរិច្ឆេទកំណត់ តាមវិធាន ២៣ស្ទួន(២) នៃវិធានផ្ទៃក្នុង[239] គឺក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីការជូនដំណឹងក្នុងឆ្នាំ២០១១ តាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង[240] ដែលជូនដំណឹងដល់ភាគី អំពីការបិទបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការ ក្នុងសំណុំរឿង០០៣។

110. សុពលភាពនៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិ លើភាពអាចទទួលយកបាននៃ

---

[236] ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D268)។

[237] ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D268) កថាខណ្ឌ ៤ យោងទៅ ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ សេង ចាន់ធារី (ឯកសារ D11/1/3) ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ Rob HAMILL (ឯកសារ D11/2/3) ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ជុំ នៅ (ឯកសារ D11/3/3) ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ Timothy Scott DEEDS (ឯកសារ D11/4/3)។ សូមមើលផងដែរ ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D268) កថាខណ្ឌ ៦ ពន្យល់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សេង ចាន់ធារី បានដកពាក្យសុំរបស់គាត់វិញ។

[238] ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D268) កថាខណ្ឌ ២។ សូមមើលផងដែរ ដីកាសម្រេចលើកលែងចោទប្រកាន (ឯកសារ D266) កថាខណ្ឌ ២, ៨, ៣៩, ៤១, ៣៥៩។

[239] ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D268) កថាខណ្ឌ ៩, ១១។

[240] សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ឆ្នាំ២០១១ (ឯកសារ D13)។

01672745



ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពឹងផ្អែកយ៉ាងច្បាស់ទៅលើការសម្រេចនៃដីកាសម្រេចលើកលែងចោទប្រកាន់[241] គឺជាការចាំបាច់ ជាប់ពាក់ព័ន្ធទាំងស្រុងជាមួយនឹងសុពលភាពផ្លូវច្បាប់នៃដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទាល់។ ដោយសារតែដីកាសម្រេចលើកលែងចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺគ្មានសុពលភាពតាំងពីដំបូង *(ab initio)* ហើយការចេញដីកាសម្រេចលើកលែងចោទប្រកាន់នេះ មិនមានមូលដ្ឋានគតិយុត្តិ នៅក្នុងក្របខណ្ឌជាសារវ័ន្តរបស់ អ.វ.ត.ក នោះ[242] ចៅក្រមអន្តរជាតិសម្រេចថា ដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏មិនមានសុពលភាពដែរ ហើយមិនមានអានុភាពគតិយុត្តិឡើយ។ ហេតុដូច្នេះ ដីកាសម្រេចលើភាពអាចទទួលយកបានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានអានុភាពជាដីកាសម្រេចដែលមានសុពលភាពតែមួយគត់ ក្នុងការសម្រេចលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣។ បន្ថែមលើនេះ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានរារាំងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាអាចទទួលយកបាន ក្នុងកិច្ចដំណើរការនីតិវិធីនាពេលអនាគតប្រឆាំងនឹង មាស មុត ឡើយ។

111. ហេតុដូច្នេះ សម្រាប់សំអាងហេតុដូចបានលើកឡើងខាងលើ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន និងបដិសេធមូលដ្ឋានទី១(១), ២, ៣ និង ៤។ ចៅក្រមអន្តរជាតិតម្កល់ផ្នែកខ្លះ និងបដិសេធផ្នែកខ្លះនៃមូលដ្ឋានទី១(១) និង ១(៣)។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងសេចក្តីសម្រេចរបស់គាត់ លើភាពអាចទទួលយកបាន ក្នុងមូលដ្ឋានទី១(១) និង ១(៣) គឺថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំ និងឯកសារពាក់ព័ន្ធ គួរត្រូវបានទទួលយកក្នុងសំណុំរឿង ០០៣ (ដូចមានសំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ១ នៃមតិយោបល់នេះ[243]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ៥ រូប ដូចតទៅនេះត្រូវបានទទួលយក៖ ឡុង វ៉ន (11-VSS-00138), អន ដារ៉ារុធ (17-VSS-00043), អ៊ុំ សាគម

[241] ដីកាសម្រេចលើពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D268) កថាខណ្ឌ ៩ យោងទៅ ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D266) កថាខណ្ឌ ១៨។

[242] សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) មតិចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៤៩-២៥០, ២៨៤, ៣៤២។

[243] សូមមើលខាងលើ កថាខណ្ឌ ៦៥ និង ៧៨-៧៩។

01672746



(14-VSS-00016), គង់ សំណាង (11-VSS-00301) និង វង់ គឹមស្ងួន (11-VSS-00293)[244]។

## វិធាន ៧៧(១៣)(ក)នៃវិធានផ្ទៃក្នុង

112. វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ចែងថា ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចមួយ គឺថាដីកាសម្រេចបែបនោះ ត្រូវតម្កល់ទុកជាបានការ។ ជាលទ្ធផល ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតម្កល់ទុកជាបានការ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានសម្រេចថាអាចទទួលយកបាន ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[245] មានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនាពេលអនាគត ប្រឆាំងនឹង មាស មុត។

**រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១**

**ចៅក្រម** Olivier BEAUVALLET

**ចៅក្រម** Kang Jin BAIK

[244] សូមមើល ឧបសម្ព័ន្ធ ១។

[245] ឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាស្តីពីភាពអាចទទួលយកបាន (ឯកសារ D269.1)។